**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économoiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈលើកដំបូង

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **សៀ ចាន់ថេត**

សាស្ត្រាចារ្យណែនាំ

លោក **ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេររបាយការណ៍ ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សៀ ចាន់ថេត** ជានិស្សិតជំនាន់ទី១៥ ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ក្រុម B4A1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើរបាយការណ៍សារណាបញ្ចប់ការសិក្សាស្រាវជ្រាវលើប្រធានបទ «**ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង**»។

សូមសម្តែងនូវការគោរព និងថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតចំពោះ៖

លោកឪពុក **ស៊ាន គឹមសៀ** និងអ្នកម្តាយ **សួន ចាន់ធូ** ជាអ្នកមានគុណបំផុតដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ប្រកបដោយសេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់ និងផ្តល់នូវគ្រប់យ៉ាង ទាំងកម្លាំងកាយ កម្លាំងចិត្ត ដ៏ធំធេងដល់កូន ចាប់តាំងពីចាប់កំណើតរហូតដល់ពេញវ័យនិងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងឡាយ ដែលបានធ្វើការបង្រៀនប្រៀនប្រដៅ ផ្តល់ចំណេះដឹង និងដំបូន្មានល្អៗដល់នាងខ្ញុំ ដោយយកចិត្តទុកដាក់រយៈពេលបួនឆ្នាំកន្លងមកនេះ។

លោកសាស្ត្រាចារ្យ **ឈាង ហ៊ុយ** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការស្រាវជ្រាវ និងសរសេរនូវសារណាមួយនេះ។ លោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ផ្តល់ជាគំនិត ជួយកែសម្រួល តាំងពីពេលចាប់ផ្តើមរហូតដល់បញ្ចប់ការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

លោក លោកស្រីសាស្ត្រាចារ្យផ្នែកធនាគារ និងហិរញ្ញវត្ថុទាំងឡាយនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាក្នុងការបង្ហាត់បង្រៀន ព្រមទាំងចែករំលែកនូវបទពិសោធន៍ និងដំបូន្មានល្អៗដល់នាងខ្ញុំ។

រៀមច្បងទាំងឡាយដែលបានបន្សល់ទុកនូវ ស្នាដៃល្អៗជាច្រើន សម្រាប់ធ្វើជាគម្រូ និងព័ត៌មានដល់នាងខ្ញុំផ្ទាល់ ដ៏ដូចជាសិស្សនិស្សិតរួមជំនាន់ និងសិស្សប្អូនជំនាន់ក្រោយៗទៀត។

មិត្តរួមថ្នាក់ B4A1 ទាំងឡាយដែលបានផ្តល់ជាយោបល់ និងកម្លាំងចិត្តដល់នាងខ្ញុំក្នុងការស្រាវជ្រាវ និងសរសេរបញ្ចប់នូវប្រធានបទនេះ។

ជាទីបញ្ចប់ នាងខ្ញុំសូមជូនពរដល់អ្នកមានគុណទាំងឡាយដែលបានរៀបរាប់ខាងលើ ឱ្យជួបតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នាងខ្ញុំជានិស្សិតជំនាន់ទី១៥ ជំនាញធនាគារ និងហិរញ្ញវត្ថុនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ឆ្នាំសិក្សា ២០២១-២០២២ បានធ្វើការស្រាវជ្រាវ និងចងក្រងកិច្ចការស្រាវជ្រាវនេះឡើងក្នុងគោលបំណង ដើម្បីពង្រីកនូវចំណេះដឹង និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ទៅលើវិស័យហិរញ្ញវត្ថុ ជាពិសេសនោះគឺវិស័យមូលបត្រនៅកម្ពុជាទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ដែលបានឆ្លងកាត់តាមរយៈការសិក្សាតាមរយៈការបង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ពីលោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យអស់រយៈពេលបួនឆ្នាំកន្លងមក។

ដើម្បីសម្រេចបានជោគជ័យនៅក្នុងការរៀបចំជាឯកសារសារណានេះឡើងមក នាងខ្ញុំបានខិតខំក្នុងការស្រាវជ្រាវ ព្រមទាំងមានការជួយជ្រោមជ្រែងពន្យល់ណែនាំ ផ្តល់ជាឯកសារ និងការផ្តល់យោបល់ល្អៗរបស់សាស្ត្រាចារ្យដឹកនាំ។

ប្រធានបទ «ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង» នេះគឺជាគំនិតស្អួចស្តើងមួយដែលលេចឡើងជារូបរាង ដោយសារការខិតខំប្រឹងប្រែងរបស់នាងខ្ញុំ ដែលនឹងអាចជាទុនមួយសម្រាប់និស្សិតជំនាន់ក្រោយៗទុកជាគំរូឯកសារក្នុងការស្រាវជ្រាវបន្តទៀត។

នាងខ្ញុំជឿជាក់ថាកិច្ចការស្រាវជ្រាវនេះនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ តែទោះជាយ៉ាងណាយើងសង្ឃឹមថា និស្សិតនិងមិត្តអ្នកអានទាំងអស់ពិតជាមានការអធ្យាស្រ័យនូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយអចេតនា។

# មាតិកា

ទំព័រ
បញ្ជីអក្សរកាត់ ........ vi
បញ្ជីតារាង ........ vii
បញ្ជីរូបភាព ........ viii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១
## រំលឹកទ្រឹស្តី

១.១. និយមន័យមូលបត្រ ........ ៥
១.២. ប្រភេទនៃមូលបត្រ ........ ៥
១.២.១. មូលបត្ររដ្ឋ ........ ៥
១.២.២. មូលបត្រមហាជន ........ ៦
១.២.២.១. មូលបត្រកម្មសិទ្ធិ ........ ៦
១.២.២.២. មូលបត្របំណុល ........ ៧
១.២.២.៣. អាជីវកម្មគម្រោងវិនិយោគរួម ........ ៩
១.២.២.៤. ឧបករណ៍ដេរីវេទីវ ........ ៩
១.៣. ទីផ្សារមូលបត្រ ........ ៩
១.៤. ប្រភេទនៃទីផ្សារមូលប័ត្រ ........ ១០
១.៤.១. ទីផ្សារដំបូង ........ ១០
១.៤.២. ទីផ្សារបន្ទាប់ ........ ១០
១.៥. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ ........ ១១

១.៦. សារៈសំខាន់នៃទីផ្សារមូលបត្រ ................................................................................................... ១២
១.៦.១. អត្ថប្រយោជន៍ទីផ្សារមូលបត្រសម្រាប់វិនិយោគិន .............................................................. ១២
១.៦.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ ............................................... ១៣
១.៦.២.១. ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង ..................................................................១៣
១.៦.២.២. ទទួលបានការលើកទឹកចិត្តពន្ធ ........................................................................................ ១៤
១.៦.២.៣. ទទួលបាននិរន្តរភាពអាជីវកម្មជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុង ដែលរឹងមាំជាងមុន ..................................................................................................... ១៤
១.៦.២.៤. ការធ្វើឱ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងភាពមើលឃើញរបស់ក្រុមហ៊ុន............................ ១៥
១.៦.២.៥. ការត្រៀមខ្លួនជាមុនចំពោះបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល ............................................. ១៥
១.៦.៣. អត្ថប្រយោជន៍ទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ...........................................................១៥

## ជំពូកទី២

## ស្ថានភាពទូទៅរបស់និយ័តករមូលបត្រ

២.១. ប្រវត្តិនិយ័តករមូលបត្រកម្ពុជា ........................................................................................... ១៦
២.២. នាមករណ៍ និងនិមិត្តសញ្ញារបស់និយ័តករមូលបត្រកម្ពុជា.......................................................... ១៦
២.៣. ត្រារបស់និយ័តករមូលបត្រកម្ពុជា..........................................................................................១៩
២.៤. ចក្ខុវិស័យរបស់និយ័តករមូលបត្រកម្ពុជា.................................................................................១៩
២.៥. បេសកម្មរបស់និយ័តករមូលបត្រកម្ពុជា...................................................................................១៩
២.៦. ទីតាំងរបស់និយ័តករមូលបត្រកម្ពុជា .....................................................................................២០
២.៧. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ................................................................................................... ២១
២.៨. មុខងាររបស់និយ័តករមូលបត្រកម្ពុជា ..................................................................................... ២១

## ជំពូកទី៣

## ស្ថានភាពទូទៅរបស់ផ្សារមូលបត្រកម្ពុជា

៣.១. ប្រវត្តិនៃទីផ្សារមូលបត្រ......................................................................................................... ២២
៣.២. ប្រវត្តិនៃទីផ្សារមូលបត្រកម្ពុជា ................................................................................................. ២២
៣.៣. នាមករណ៍ និងនិមិត្តសញ្ញារបស់ផ្សារមូលបត្រកម្ពុជា................................................................២៤
៣.៤. ចក្ខុវិស័យរបស់ផ្សារមូលបត្រកម្ពុជា.........................................................................................២៤
៣.៥. បេសកម្មក្រុមហ៊ុនមូលបត្រកម្ពុជា............................................................................................២៤
៣.៦. ទីតាំងរបស់ផ្សារមូលបត្រកម្ពុជា ...............................................................................................២៥

៣.៧. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ....................................................................................................................................២៦
៣.៨. តួនាទីទីផ្សារមូលបត្រក្នុងសេដ្ឋកិច្ច ........................................................................................................................២៦

## ជំពូកទី៤
## ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

៤.១. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) ..........................................២៨
៤.២. តួអង្គសំខាន់ៗក្នុងដំណើរការនៃការធ្វើ IPO ..........................................................................................២៨
៤.២.១. និយ័តករមូលបត្រកម្ពុជា...................................................................................................................២៩
៤.២.២. ផ្សារមូលបត្រកម្ពុជា...........................................................................................................................២៩
៤.២.២.១. ប្រតិបត្តិករទីផ្សារមូលបត្រ ...........................................................................................................២៩
៤.២.២.២. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ...................................................................................២៩
៤.២.២.៣. ប្រតិបត្តិការរក្សាទុកមូលបត្រ ........................................................................................................២៩
៤.២.៣. ក្រុមហ៊ុនមូលបត្រ...............................................................................................................................២៩
៤.២.៣.១. អាជីវកម្មធានាទិញមូលបត្រ .........................................................................................................២៩
៤.២.៣.២. អាជីវកម្មជួញដូរមូលបត្រ...............................................................................................................៣១
៤.២.៣.៣. អាជីវកម្មជើងសាមូលបត្រ..............................................................................................................៣១
៤.២.៣.៤. អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ .......................................................................................................៣១
៤.២.៤. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ...................................................................................................... ៣២
៤.២.៥. វិនិយោគិន ....................................................................................................................................... ៤០
៤.៣. ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ..........................................................................................៤១
៤.៣.១. គោលបំណង និងវិសាលភាពនៃអនុក្រឹតស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ.........៤១
៤.៣.២. ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល..................................................................................................៤១
៤.៣.៣. ការលើកទឹកចិត្តពន្ធកាត់ទុក ............................................................................................................ ៤៣
៤.៤. យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ............................................. ៤៣
៤.៤.១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ.............................................................. ៤៣
៤.៤.២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ.......................................................................................... ៤៤
៤.៤.៣.ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ...................................................................... ៤៤
៤.៤.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ .................................................................................. ៤៤

៤.៤.៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការបញ្ជាក់ពី ផ.ម.ក........... ៤៤
៤.៤.៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងការទទួលអនុញ្ញាតពី ន.ម.ក........... ៤៥
៤.៤.៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង........ ៤៥
៤.៤.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពី ផ.ម.ក........ ៤៥
៤.៤.៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក........ ៤៥
៤.៤.១០. ការធ្វើបរិវិសកម្មមូលបត្រ........ ៤៥
៤.៤.១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ........ ៤៦
៤.៤.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រ........ ៤៦
៤.៥. លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ........ ៤៦
៤.៦. លក្ខខណ្ឌនៃការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ........ ៤៧
៤.៧. លក្ខណៈវិនិច្ឆ័យដែលគួរតែពិចារណាក្នុងការចុះបញ្ជី........ ៤៨
៤.៧.១. លក្ខខណ្ឌតម្រូវជាតួលេខ........ ៤៨
៤.៧.២. លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ........ ៤៩
៤.៨. និតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ........ ៥០
៤.៨.១. ការដាក់ពាក្យស្នើសុំ........ ៥០
៤.៨.២. ឯកសារផ្តល់ព័ត៌មាន........ ៥១
៤.៨.៣. ឯកសារភ្ជាប់........ ៥២
៤.៩. យន្តការនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម........ ៥៣
៤.៩.១. ដំណាក់កាលប៊ុកបៀលឌីង........ ៥៣
៤.៩.២. ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ........ ៥៤
៤.១០. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ........ ៥៥
៤.១០.១. ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ........ ៥៥
៤.១០.២. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ........ ៥៦
៤.១១. ពិភាក្សាទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង........ ៥៦
៤.១១.១. ចំណុចខ្លាំង........ ៥៧

៤.១១.២. ចំណុចខ្សោយ........................................................................................................៥៧
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**.........................................................................................៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.ម.ក. | ៖ គណៈកម្មការមូលបត្រកម្ពុជា |
| ន.ម.ក. | ៖ និយ័តករមូលបត្រកម្ពុជា |
| ផ.ម.ក. | ៖ ផ្សារមូលបត្រកម្ពុជា |
| ផ.ស.ស. | ៖ ផលិតផលក្នុងស្រុកសរុប |
| ABC | ៖ ACLEDA Bank Plc. |
| CSX | ៖ Cambodia Securities Exchange |
| DBDE | ៖ DBD Engineering Plc. |
| GTI | ៖ Grand Twins International (Cambodia) Plc. |
| IPO | ៖ Initial Public Offering ឬ ដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង |
| JSL | ៖ JS LAND PLC |
| PAS | ៖ Sihanoukville Autonomous Port |
| PEPC | ៖ Pestech (Cambodia) Plc. |
| PPAP | ៖ Phnom Penh Autonomous Port |
| PPSP | ៖ Phnom Penh SEZ Plc. |
| PWSA | ៖ Phnom Penh Water Supply Authority |
| SERC | ៖ Securities and Exchange Regulator of Cambodia |

# បញ្ជីតារាង

ទំព័រ

តារាងទី១ ៖ លទ្ធផលនៃ IPO របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ......................................... ៣៣

តារាងទី២ ៖ លទ្ធផលនៃ IPO របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អិនធើណេសិនណាល ភីអិលស៊ី ............. ៣៤

តារាងទី៣ ៖ លទ្ធផលនៃ IPO របស់កំពង់ផែស្វយ័តភ្នំពេញ ................................................. ៣៥

តារាងទី៤ ៖ លទ្ធផលនៃ IPO របស់ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត ......................................... ៣៦

តារាងទី៥ ៖ លទ្ធផលនៃ IPO របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ....................................... ៣៧

តារាងទី៦ ៖ លទ្ធផលនៃ IPO របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ......................................... ៣៨

តារាងទី៧ ៖ លទ្ធផលនៃ IPO របស់ផេសថិក (ខេមបូឌា) .................................................. ៣៩

តារាងទី៨ ៖ លទ្ធផលនៃ IPO របស់ឌី ប៊ី ឌី អ៊ិនជីនារីង........................................................ ៤០

តារាងទី៩ ៖ លទ្ធផលនៃ IPO របស់ជេអេស លែន ភីអិលស៊ី.................................................. ៤១

តារាងទី១០ ៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ............................................................... ៥៧

តារាងទី១១ ៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ .................................................. ៥៨

# បញ្ជីរូបភាព

ទំព័រ


| | | |
|---|---|---|
| រូបទី១ | ៖ និមិត្តសញ្ញាចាស់របស់ គ.ម.ក | ១៧ |
| រូបទី២ | ៖ និមិត្តសញ្ញាថ្មីរបស់ ន.ម.ក. | ១៨ |
| រូបទី៣ | ៖ ត្រារបស់និយ័តករមូលបត្រកម្ពុជា | ២០ |
| រូបទី៤ | ៖ ទីស្តីការថ្មីរបស់និយ័តករមូលបត្រកម្ពុជា | ២១ |
| រូបទី៥ | ៖ រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា | ២២ |
| រូបទី៦ | ៖ និមិត្តសញ្ញាផ្សារមូលបត្រកម្ពុជា | ២៥ |
| រូបទី៧ | ៖ ទីតាំងផ្សារមូលបត្រកម្ពុជា | ២៦ |
| រូបទី៨ | ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ផ្សារមូលបត្រកម្ពុជា | ២៧ |
| រូបទី៩ | ៖ និមិត្តសញ្ញា PPWSA | ៣៣ |
| រូបទី១០ | ៖ និមិត្តសញ្ញា GTI | ៣៤ |
| រូបទី១១ | ៖ និមិត្តសញ្ញា PPAP | ៣៥ |
| រូបទី១២ | ៖ និមិត្តសញ្ញា PPSP | ៣៦ |
| រូបទី១៣ | ៖ និមិត្តសញ្ញា PAS | ៣៧ |
| រូបទី១៤ | ៖ និមិត្តសញ្ញា ABC | ៣៨ |
| រូបទី១៥ | ៖ និមិត្តសញ្ញា PEPC | ៣៩ |
| រូបទី១៦ | ៖ និមិត្តសញ្ញា DBDE | ៤០ |
| រូបទី១៧ | ៖ និមិត្តសញ្ញា JSL | ៤១ |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលធ្លាប់បានឆ្លងកាត់នូវសង្គ្រាមជាច្រើនទសវត្សរ៍មកហើយ។ បន្ទាប់ពីទទួលបានសន្តិភាពយ៉ាងពេញលេញ រដ្ឋាភិបាលបានខិតខំអភិវឌ្ឍប្រទេសដូចជា កសាង សាលារៀន មន្ទីរពេទ្យ ផ្លូវ ថ្នល់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដើម្បីទាក់ទាញការបណ្តាក់ទុនពីក្រៅប្រទេសមក។ បន្ទាប់ពីនេះយើងឃើញថាកម្ពុជាទទួលបានការបណ្តាក់ទុនពីក្រៅប្រទេសមកជាច្រើន និងបានធ្វើឱ្យគ្រប់វិស័យទាំងឡាយបានរីកចម្រើន ជាពិសេសនោះគឺវិស័យសេដ្ឋកិច្ច។

ជាក់ស្តែងក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយមុននឹងវិបត្តិកូវីដ-១៩ ពោលគឺអំឡុងឆ្នាំ២០១៧-២០១៩ កម្ពុជារក្សាបាននូវស្ថិរភាពពេញលេញ និងមានស្ថិរភាពនយោបាយរឹងមាំ ព្រមទាំងសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពក្នុងអត្រាជាមធ្យម៧ភាគរយក្នុងមួយឆ្នាំ។[1] ក្នុងនោះផងដែរវិស័យហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិស័យឯកជន និងធានាចីរភាពនៃកំណើនសេដ្ឋកិច្ច។ រដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ចេញជាផ្លូវការនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរៀងរាល់១០ឆ្នាំម្តង។ នៅក្នុងឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានសម្រេចធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រជាលើកទី៣ នោះគឺយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ ដែលធ្វើឱ្យវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុបន្តមានកំណើនខ្ពស់ ស្របពេលដែលវិស័យធានារ៉ាប់រងក៏មានការរីកចម្រើនជាបន្តបន្ទាប់។[2] ក្រៅពីនេះ ទីផ្សារមូលបត្រក៏ជាប្រភពដ៏សំខាន់មួយដែលផ្តល់ជាមូលធនដល់វិនិយោគិន ក្នុងការប្រើប្រាស់ក្នុងការវិនិយោគ ឬទ្រទ្រង់អាជីវកម្មរបស់ខ្លួន ក៏ដូចជាជំរុញការអភិវឌ្ឍប្រទេសផងដែរ។

ដើម្បីជាផ្នែកមួយនៃការជំរុញ ក្នុងការពង្រីកការប្រើប្រាស់ក៏ដូចជាអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែល្អប្រសើរ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឱ្យដំណើរការ គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ដែលជានិយ័តករមូលបត្រ ក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជននៅឆ្នាំ ២០០៨ និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក.**) នៅឆ្នាំ២០១១។ ចាប់តាំងពីដាក់ឱ្យដំណើរការមកទាំង គ.ម.ក. និង ផ.ម.ក. បានប្រតិបត្តិមុខងាររបស់ខ្លួន ក្នុងការដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ភាពងាយស្រួលដល់វិនិយោគិនក្នុងនិងក្រៅប្រទេសក្នុងការស្វែងរកការវិនិយោគ និងធ្វើឱ្យកាន់តែមានការដឹងលឺកាន់តែខ្លាំងនូវលើវិស័យមូលបត្រនៅប្រទេសកម្ពុជាយើង។

---

[1] GDP growth (annual %) - Cambodia | Data, https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?end=2020&locations=KH&name_desc=false&start=1994 (ចូលថ្ងៃទី ២៦ មីនា ២០២២)

[2] យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥

ដោយមើលឃើញពីការសារៈសំខាន់ពីវិស័យទីផ្សារមូលបត្រនេះហើយ ទើបនាងខ្ញុំបានសម្រេចចិត្តលើកយកប្រធានបទ «ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង» មកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីឱ្យសិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាសាធារណៈជន បានយល់ដឹងបន្ថែមពីទីផ្សារមូលបត្រ និងនិតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធរបស់និយ័តករមូលបត្រកម្ពុជា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រជាវិស័យមួយដែលចាត់ទុកថាជាកម្លាំងចលករមួយដែលជំរុញកំណើនសេដ្ឋកិច្ច ដោយការផ្តល់នូវមូលធនដល់វិនិយោគិនកម្ពុជា។ ទីផ្សារមូលបត្រនៅកម្ពុជា មិនទាន់មានច្រើននៅឡើយ ទើបតែមានជាងមួយសតវត្សនេះតែប៉ុណ្ណោះ ដូចនេះហើយវិស័យនេះនៅមានភាពវ័យក្មេង ខ្វះបច្ចេកវិទ្យា និងវិធីសាស្ត្រនូវក្នុងការអភិវឌ្ឍនៅមានកម្រិតនូវឡើយ។ បើទោះបីជាមានការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ក្នុងការពង្រីកវិស័យនេះឱ្យកាន់តែមានការដឹងឮច្រើនយ៉ាងណាក្តីក៏ប្រជាជន និងអ្នកវិនិយោគមួយចំនួនហាក់ដូចជាមិនទាន់យល់ដឹងច្បាស់ពីវិស័យនេះឡើយ។ ដោយសារតែបែបនេះហើយ ទើបបានប្រធានបទនេះត្រូវបានលើកយកមកធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយឱ្យបានច្បាស់បន្ថែមទៀត។ នៅក្នុងនោះដែលយើងគួរយល់ដឹងថា៖

- តើដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងមានអ្វីខ្លះ ?
- តើវិនិយោគិនត្រូវការបំពេញតាមលក្ខខណ្ឌអ្វីខ្លះ ដើម្បីធ្វើការការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពី «ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង» គឺផ្តោតទៅលើប្រតិបត្តិការនៃការបោះផ្សាយមូលបត្រសាធារណៈលើកដំបូង។ គោលបំណងជាក់លាក់ក្នុងការស្រាវជ្រាវសំខាន់ៗគឺ៖

- ស្វែងយល់ឱ្យកាន់តែច្បាស់ពីនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ស្គាល់អំពីដំណើរការនៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង
- ស្វែងយល់អំពីលក្ខខណ្ឌទូទៅនៃការបោះផ្សាយមូលបត្រនៅកម្ពុជា
- ស្វែងយល់ពីនិតិវិធិក្នុងការការបោះផ្សាយមូលបត្រ
- យល់ដឹងអំពីតួអង្គសំខាន់ៗចូលរួមសហការ
- ការធ្វើសេចក្តីសន្និដ្ឋាន
- ការផ្តល់អនុសាសន៍

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាទៅលើវិស័យមូលបត្រ មានលក្ខណៈធំទូលាយ និងមានរយៈច្រើនឆ្នាំបើគិតចាប់ពីពេលដំណើរការដំបូង រហូតមកដល់បច្ចុប្បន្ននេះ។ ដូចនេះហើយទើបការសិក្សាលើប្រធានបទមួយនេះ គឺផ្តោតសំខាន់តែលើដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) ជាមួយទិន្នន័យឆ្នាំ ២០២២ ត្រឹមខែមេសា តែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

- **ការប្រមូលទិន្នន័យ**

ការប្រមូលទិន្នន័យ និងព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវលើប្រធានបទនេះគឺពឹងផ្អែកលើប្រភពទិន្នន័យដែលមានស្រាប់ (បន្ទាប់បន្សំ) រួមមាន៖

- គេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក.)
- គេហទំព័រផ្សារមូលបត្រកម្ពុជា (ផ.ម.ក)
- ច្បាប់ អនុក្រឹត្ត និងប្រកាសនានាដែលចេញដោយរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងមូលបត្រ
- ឯកសារសារណាបញ្ចប់ការសិក្សារបស់សិស្សច្បងជំនាន់មុនៗ
- ឯកសាររបស់សាស្ត្រចារ្យ
- គេហទំព័រផ្លូវការនានា

- **ការវិភាគទិន្នន័យ**

បន្ទាប់ពីប្រមូលទិន្នន័យរួច ដំណាក់កាលបន្ទាប់នេះគឺត្រូវធ្វើការវិភាគទិន្នន័យតាមបែបគុណវិស័យ ឬបែបពណ៌នាដើម្បីធ្វើការបកស្រាយអោយបានច្បាស់លាស់នូវអត្ថន័យនៃការសិក្សាស្រាវជ្រាវនេះ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ «ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង» នេះបានផ្តល់អត្ថប្រយោជន៍ដូចជា៖

- **ចំពោះនាងខ្ញុំផ្ទាល់**
  - ផ្តល់ជាចំណេះដឹងកាន់តែច្បាស់ពីវិស័យមូលបត្រ ដោយបានផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីទាំងឡាយដែលបានសិក្សាកន្លងមក
  - យល់ដឹងបន្ថែមពីរបៀបស្វែងរកឯកសារ និងទិន្នន័យផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទ
  - ចេះពីវិធីក្នុងការរៀបចំឯកសារ និងធ្វើការបកស្រាយពីលទ្ធផលដែលបានពីការស្រាវជ្រាវ
  - ចងក្រងទុកជាឯកសារយោងដល់អ្នកជំនាន់ក្រោយ

- ទទួលបានបទពិសោធន៍បន្ថែមទាក់ទងនឹងការសិក្សាស្រាវជ្រាវ
- រំលឹកបន្ថែមពីមេរៀនដែលធ្លាប់បានសិក្សាកន្លងមក
- ចេះរៀបចំឯកសារ និងប្រមូលទិន្នន័យនានា ដើម្បីមកធ្វើការចងក្រង

➢ **ចំពោះនិស្សិត និងអ្នកសិក្សាស្រាវជ្រាវ**

- ស្វែងយល់ពីទីផ្សារមូលបត្រកម្ពុជា
- យល់ដឹងអំពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ
- យល់ដឹងពីលក្ខខណ្ឌនៃការបោះផ្សាយលក់មូលបត្រ
- ដឹងអំពីព័ត៌មាននានាពាក់ព័ន្ធនឹងទីផ្សារមូលបត្រនៅកម្ពុជា
- ស្គាល់កាន់តែច្បាស់អំពីការបោះផ្សាយមូលបត្រ
- ផ្តល់ជាទុនបន្ថែមដល់ការសិក្សាស្រាវជ្រាវបន្ថែមទៀត

➢ **មជ្ឈដ្ឋានទូទៅ**

- ផ្តល់ជាព័ត៌មានសម្រាប់វិនិយោគិន ដែលមានបំណងចង់ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ
- ជាឯកសារសម្រាប់អ្នកអានទូទៅ ដើម្បីទទួលបានចំនេះដឹងបន្ថែមពីវិស័យមូលបត្រនេះ
- ផ្តល់ជាគំនិតមួយចំនួនដល់ស្ថាប័នពាក់ព័ន្ធ ដើម្បីកែលម្អលើចំនុចខ្វះខាតក្នុងដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិ

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើប្រធានបទ «ដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសារធារណៈលើកដំបូង»៖



# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. និយមន័យមូលបត្រ

មូលបត្រ (Securities) គឺជាឧបករណ៍ហិរញ្ញវត្ថុទាំងឡាយដែលតំណាងឱ្យភាពជាម្ចាស់កម្មសិទ្ធិលើក្រុមហ៊ុនសាធារណៈ ឬជាម្ចាស់ឥណទានទៅលើស្ថាប័នរដ្ឋាភិបាល ឬក្រុមហ៊ុនសាជីវកម្ម។[3]

## ១.២. ប្រភេទនៃមូលបត្រ

យោងទៅតាមមគ្គុទេសក៏ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសារធារណៈនៅព្រះរាជាណាចក្រកម្ពុជា នៅកម្ពុជាយើង មូលបត្រអាចត្រូវបានបែងចែកជា ២ ប្រភេទធំៗ គឺមូលបត្ររដ្ឋ និងមូលបត្រមហាជន។[4]

### ១.២.១. មូលបត្ររដ្ឋ

យោងតាមច្បាប់ស្តីពីមូលបត្ររដ្ឋបានចែងថា មូលបត្ររដ្ឋ (Government Securities) គឺសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានផ្សាយក្នុងនាមរដ្ឋាភិបាលនៅក្រោមច្បាប់ស្តីពីមូលបត្ររដ្ឋ រួមមាន[5]៖

- បណ្ណរតនាគារដែលមានឥណទានប្រតិទានតិចជាងមួយឆ្នាំ
- សញ្ញាបណ្ណរតនាគារដែលមានឥណទានប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ
- សញ្ញាបណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអត្រាអធិរណា ឬ អត្រាប្តូរប្រាក់ ឬ អត្រាផ្សេងៗ
- មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ
- មូលបត្ររដ្ឋផ្សេងៗដទៃទៀត

មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រ ដែលបោះផ្សាយដោយអាជ្ញាធរ ខេត្ត-ក្រុង និងសហគ្រាសសាធារណៈ ឬការសុំខ្ចីផ្សេងៗរបស់រដ្ឋាភិបាលដែលមិនស្របទៅនឹងច្បាប់ស្តីអំពីមូលបត្ររដ្ឋទេ។

មូលបត្ររដ្ឋអាចត្រូវបានបោះផ្សាយជារូបិយវត្ថុជាតិ ឬជារូបិយបណ្ណបរទេសដូចជា៖

- **សញ្ញាបណ្ណបំណុលទូទៅ និងសញ្ញាបណ្ណប្រាក់ចំណូល (General Obligation and Revenue**

[3] សុធី មេត្តា, «ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា,» (និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច,២០២០), ទំព័រទី៧

[4] និយ័តករមូលបត្រកម្ពុជា, មគ្គុទេសក៏ស្តីពី ការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសារធារណៈនៅព្រះរាជាណាចក្រកម្ពុជា, (ភ្នំពេញ៖ គ.ម.ក, ២០១៧), ទំព័រទី៣

[5] ច្បាប់ស្តីពីមូលបត្ររដ្ឋ, លេខ នស/រកម/០១០៧/០០១, ១០ មករា ២០០៧, មាត្រាទី២

**Bonds)**៖ ជាទូទៅសំដៅលើសញ្ញាបណ្ណរបស់រដ្ឋាភិបាល។ វាទទួលបានភាពជឿជាក់ខ្ពស់ និងត្រូវបានធានាដោយអំណាចពន្ធ។ ភ្នាក់ងារដែលទទួលបានសិទ្ធិបោះផ្សាយសញ្ញាបណ្ណបំណុលនេះគឺមានតែភ្នាក់ងាររបស់ប្រទេសមួយ ឬសាលាក្រុងមួយ។

- **សញ្ញាបណ្ណរតនាគារ ឬរដ្ឋាភិបាល (Treasury Bonds)**៖ នៅពេលមានតម្រូវការថវិកាជាតិដើម្បីធ្វើហិរញ្ញប្បទានរយៈពេលវែង រដ្ឋាភិបាលអាចចេញលក់ធ្វើការបោះផ្សាយមូលបត្របំណុលប្រភេទនេះដែលជាធម្មតាមានអាយុកាល ២០ ទៅ៣០ឆ្នាំ។ ជាទូទៅ សញ្ញាបណ្ណប្រភេទនេះមានជម្រើសមួយដែលអ្នកបោះផ្សាយអាចធ្វើការទូទាត់សងមុនការកំណត់បានក្រោយរយៈពេលព្រមព្រៀងគ្នាមួយ។
- **បណ្ណរតនាគារ (Treasury Notes)**៖ វាត្រូវបានគេហៅថាឧបករណ៍វិនិយោគរយៈពេលមធ្យម ព្រោះថាជាទូទៅវាមានឥណប្រទិទានពី២ទៅ១០ឆ្នាំ។ បណ្ណរតនាគារមិនអាចទិញត្រឡប់វិញមុនកាលបរិច្ឆេទដូចសញ្ញារតនាគារនោះទេ ហើយបណ្ណរតនាគារជាធម្មតាផ្តល់ការប្រាក់រយៈពេល៦ខែម្តង។
- **បណ្ណបំណុលរតនាគារ (Treasury Bills)**៖ មូលបត្របំណុលរយៈពេលខ្លី ដែលជាមធ្យមវាមាន អាយុកាល ៣, ៦, ៩, ឬ១២ខែ។ T-Bills មិនមានការផ្តល់ជូនជាការប្រាក់ ឬ គូប៉ុនទេ ដោយសារវាមានអាយុការខ្លីពេក។ ជំនួសមកវិញគេដាក់លក់វានៅតម្លៃ Discount (តម្លៃក្រោមតម្លៃចារឹក) ហើយនៅពេលដល់អាយុកាលគេនឹងទទួលបានតម្លៃចារឹកវិញ។

### ១.២.២. មូលបត្រមហាជន

មូលបត្រមហាជន (Non-government Securities) សំដៅដល់មូលបត្រដែលបោះផ្សាយដោយក្រុម-ហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងៗទៀត ដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូល-បត្រជាសារធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយអនុលោមតាមច្បាប់។ មូលបត្រទាំងនោះមានដូចជា[6]៖

- មូលបត្រកម្មសិទ្ធិរាប់បញ្ចូលទាំងភាគហ៊ុន
- មូលបត្របំណុល រាប់បញ្ចូលទាំងសញ្ញាបណ្ណ
- ផលប្រយោជន៍ក្នុងគម្រោងវិនិយោគរួម
- ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ
- ឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដែលកំណត់ថាជាមូលបត្រ។

#### ១.២.២.១. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ (Equity Securities) គឺជាឧបករណ៍ហិរញ្ញវត្ថុដែលតំណាងឱ្យភាពជាកម្មសិទ្ធិរបស់អង្គភាពបោះផ្សាយ។ មូលបត្រកម្មសិទ្ធិបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីគៀងគរមូលនិធិពី

[6] និយ័តករមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រ៖ ប្រភេទមូលបត្រនៅកម្ពុជា (លេខ៣៥ ចេញផ្សាយឆ្នាំ២០១៩)

សាធារណៈជន។ អ្នកដែលកាន់កាប់មូលបត្រនេះនឹងទទួលបានផលប្រយោជន៍ ឬសិទ្ធស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត។ ក្រៅពីនេះ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។ ភាគហ៊ុនិកគឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួលនូវការចែករំលែកភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។

ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ទីផ្សារភាគហ៊ុនទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់វិនិយោគិន និងសារធារណជនទូទៅ។ ភាគហ៊ុន (Stock) ឬមូលបត្រកម្មសិទ្ធ (Equity Securities) ត្រូវបានបែងចែកជាពីរប្រភេទគឺ ភាគហ៊ុនធម្មតា (Common Stocks) និងភាគហ៊ុនបុរិមា (Preference Stocks)។[7]

**ក. ភាគហ៊ុនធម្មតា**

ភាគហ៊ុនធម្មតា (Common Stocks) ជាប្រភេទភាគហ៊ុនដែលតំណាងឱ្យភាពជាម្ចាស់កម្មសិទ្ធិលើក្រុមហ៊ុន សាជីវកម្មណាមួយដែលបោះផ្សាយលក់។ ភាពជាម្ចាស់នេះនឹងផ្តល់ឱ្យភាគហ៊ុនិកនូវសិទ្ធិបោះ ឆ្នោតក្នុងការចាត់ចែង ក្រុមហ៊ុន និងប្រាក់ចំណេញ ឬភាគលាភទៅតាមចំនួនភាគហ៊ុនដែលបានកាន់កាប់។ អ្នកកាន់កាប់ភាគហ៊ុនធម្មតានេះ នឹងទទួលបានការទូទាត់ក្រោយអ្នកកាន់កាប់មូលបត្រផ្សេងៗទៀតរបស់ក្រុមហ៊ុនដូចជាសញ្ញាបណ្ណ និងភាគហ៊ុនបុរិមា។

**ខ. ភាគហ៊ុនបុរិមា**

ភាគហ៊ុនបុរិមា (Preference Stocks) ជាភាគហ៊ុនទាំងឡាយណាដែលអ្នកកាន់កាប់មានសិទ្ធិទទួលបានការបែង ចែកភាគលាភមុនភាគហ៊ុនធម្មតា និងទទួលបានចំណូលថេរហើយទៀងទាត់តាមការកំណត់របស់ក្រុមហ៊ុន។ អ្នកកាន់កាប់ភាគហ៊ុនបុរិមានេះ មិនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុនដូចអ្នកកាន់កាប់ភាគហ៊ុនធម្មតានោះទេ។

**១.២.២.២. មូលបត្របំណុល**

មូលបត្របំណុល (Debt Securities) សំដៅដល់សញ្ញាបណ្ណសាជីវកម្ម (Corporate Bond) ដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដើម្បីទទួលបានសាច់ប្រាក់ក្នុងរយៈពេលកំណត់មួយ ដោយផ្តល់ដល់អ្នកកាន់កាប់មូលបត្រនេះនូវអត្រាការប្រាក់ថេរ (គូប៉ុង-Coupon Rate)។ មូលបត្របំណុលមានតម្លៃចារឹក ដោយកំណត់ចំនួនសាច់ប្រាក់ ត្រូវសងទៅអ្នកកាន់កាប់មូលបត្រវិញនៅពេលមូលបត្រនេះ ដល់កាលកំណត់មួយដែលបានព្រមព្រៀងគ្នា។

អ្នកទិញមូលបត្របំណុល នឹងទទួលបានការប្រាក់ជាប្រចាំរៀងរាល់ឆមាស ឬប្រចាំឆ្នាំ ហើយនៅពេល

[7] និយ័តករមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រ៖ ភាគហ៊ុនធម្មតា និង ភាគហ៊ុនបុរិមា (ចេញផ្សាយប្រចាំសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០១៦)

ដល់កាលបរិច្ឆេទដែលបានកំណត់ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវសងប្រាក់ដើម ដល់វិនិយោគិនវិញតាមតម្លៃដែលបានចារឹក លើមូលបត្របំណុលនីមួយៗ។

មូលបត្របំណុល ឬ សញ្ញាបណ្ណនេះត្រូវបានគេបែងចែកជាច្រើនប្រភេទដូចជា[8]៖

- **សញ្ញាបណ្ណចែករំលែកប្រាក់ចំណេញ (Participating Bonds)**៖ សញ្ញាបណ្ណប្រភេទនេះ មិនត្រឹមតែផ្ដល់អត្រាការប្រាក់ក្នុងកម្រិតថេរមួយនោះទេ ប៉ុន្តែថែមទាំងមានការចែករំលែកប្រាក់ចំណេញផងដែរ។ អ្នកកាន់កាប់សញ្ញាបណ្ណនេះ មានសិទ្ធិចូលរួមជាមួយភាគហ៊ុនិកដ៏ទៃទៀតក្នុងការចែកប្រាក់ចំណេញរបស់សាជីវកម្មដែលទទួលបាននៅក្នុងទំហំមួយដូចមានចែងនៅក្នុងកិច្ចសន្យាទិញសញ្ញាបណ្ណ។
- **សញ្ញាបណ្ណដែលអាចប្ដូរបាន (Convertible Bonds)**៖ គឺជាសញ្ញាបណ្ណមួយដែលនៅឥណប្រតិទាន ឬនៅក្នុងកាលបរិច្ឆេទដែលបានបញ្ជាក់ណាមួយនោះ សញ្ញាបណ្ណអាចត្រូវបានគេប្ដូរទៅជាចំនួនណាមួយនៃភាគហ៊ុនដែលអាចបោះឆ្នោតបាននៅក្នុងក្រុមហ៊ុនសាជីវកម្ម។
- **សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ (Zero Coupon Bonds)**៖ សំដៅទៅសញ្ញាបណ្ណដែលត្រូវបានបោះផ្សាយលក់នៅតម្លៃអប្បហារ (Discount) នៃតម្លៃចារឹក។ សញ្ញាបណ្ណប្រភេទនេះពុំមានបង់ការប្រាក់ទេ។ វិនិយោគិនទទួលប្រាក់ចំណេញពេលទទួលបានតម្លៃចារឹកពេលវាដល់អាយុកាល។
- **សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់ (High Yield or Junk Bonds)**៖ ជាប្រភេទសញ្ញាបណ្ណទាំងឡាយណាដែលត្រូវបានវាយតម្លៃនៅក្រោមកម្រិតវិនិយោគ (Low rating)។ Junk Bonds ជាសញ្ញាបណ្ណដែលមានគុណភាពអន់ តែទទួលបានទិន្នផលខ្ពស់ដើម្បីឱ្យមានភាពសមាមាត្រនឹងការប្រថុយប្រថានក្នុងការវិនិយោគ។
- **សញ្ញាបណ្ណសន្ទស្សន៍ថ្លៃ (Indexed Bonds)**៖ សញ្ញាបណ្ណទាំងនេះត្រូវបានប្រើប្រាស់ក្នុងរយៈពេលដែលមានអតិផរណាខ្ពស់។ ការទូទាត់ការប្រាក់នៃសញ្ញាបណ្ណប្រភេទនេះ ត្រូវបានធ្វើជាតារាងរៀងទៅតាមអត្រាអតិផរណា។
- **ផលបត្រពាណិជ្ជកម្ម (Commercial Paper)**៖ ជាបណ្ណបំណុលមានរយៈពេលខ្លីដែលចេញដោយក្រុមហ៊ុនសាជីវកម្មល្បីៗ។ ផលបត្រពាណិជ្ជកម្មមានកាលបរិច្ឆេទឥណប្រតិទានមួយច្បាស់លាស់ដែលមិនលើសពីមួយឆ្នាំ។ ផលបត្រពាណិជ្ជកម្មជាបណ្ណដែលមិនមានការធានា (Unsecured Promissory Note) ដែលបោះផ្សាយលក់ក្នុងតម្លៃអប្បហារ។ ការប្រាក់របស់ផលបត្រពាណិជ្ជកម្មជាធម្មតាត្រូវបង់តែនៅពេលកាលបរិច្ឆេទឥណទាន។

[8] បៀន សាំង, មូលដ្ឋានគ្រឹះទីផ្សារមូលបត្រ ( សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច,២០១១ ), ទំព័រ ២៧-៣៤

### ១.២.២.៣. អាជីវកម្មគម្រោងវិនិយោគរួម

អាជីវកម្មគម្រោងវិនិយោគរួម (Collective Investment Schemes) គឺជាប្រភេទអាជីវកម្មមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគណាមួយ អាចធ្វើការប្រមូលមូលនិអិ ឬសាច់ប្រាក់ពីវិនិយោគក្នុងគម្រោង ដែលបានកំណត់ជាក់លាក់ណាមួយ ហើយក្រុមហ៊ុនវិនិយោគនោះត្រូវធ្វើការបែងចែកប្រាក់ចំណេញត្រលប់មកវិញសមាមាត្រ តាមចំនួនដែលវិនិយោគិនបានចូលរួម។ ដើម្បីអាចដំណើរការអាជីវកម្មគម្រោងវិនិយោគរួមនេះបានចាំបាច់ត្រូវមានការចូលរួមពីតួអង្គសំខាន់ៗមួយចំនួនដូចជា៖

- ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ
- ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស
- ក្រុមហ៊ុនអភិបាលមូលនិធិ
- ក្រុមហ៊ុនចែកចាយ លក់ទិញ ត្រលប់មកវិញ ឬទូទាត់សង។

### ១.២.២.៤. ឧបករណ៍ដេរីវេទីវ

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ (Derivative Instrument) សំដៅលើកិច្ចសន្យាលើគម្លាតថ្លៃ (Contract For Difference) នៃឧបករណ៍ហិរញ្ញវត្ថុដើមដែលចេញពីមូលបត្រកម្មសិទ្ធ មូលបត្របំណុល សន្ទស្សន៍ លោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ កសិផល រូបិយបណ្ណ រួមទាំងគម្រោងការពារថ្លៃដើម (Principle Protected Scheme) ជាដើម និងដែលត្រូវបានជួញដូរក្នុងទីផ្សារ។ ឧបករណ៍និស្សន្ទទាំងនេះ គឺជាឧបករណ៍ហិរញ្ញវត្ថុដែលជាប្រភេទមួយនៃមូលបត្រ។ ឧបករណ៍និស្សន្ទ ទាក់ទងនឹងមូលបត្រមានន័យថា កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចទាក់ទងនឹងសន្តិសុខមូលដ្ឋាន រួមទាំងសិទ្ធិ ឬកាតព្វកិច្ចក្នុងការទិញលក់ ឬជាវមូលបត្រនៅថ្ងៃអនាគត ដោយមិនគិតពីថាតើបុគ្គលនោះមានបំណងប្រើប្រាស់សិទ្ធិនោះឬអត់។[9]

## ១.៣. ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ (Securities Market) គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ តាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន "សំដៅដល់ទីផ្សារឬទីកន្លែងជួញដូរមូលបត្រឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ផ្ទេរឬស្វីការទិញ-លក់មូលបត្រ"។ ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះរួមមានមូលបត្រកម្មសិទ្ធិមូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។

ជាទូទៅយើងតែងតែស្គាល់ទីផ្សារមូលបត្រថាជា «ទីផ្សារភាគហ៊ុន» ពីព្រោះផលិតផលដែលលក់ដំបូងគេនៅលើទីផ្សារនេះគឺភាគហ៊ុន។ ហេតុដូចនេះហើយ ទើបគេហៅទីផ្សារនេះថាជាទីផ្សារភាគហ៊ុននៅដំណាក់-

[9] ហេងច័ន្ទបូលីន, ប្រភេទនៃមូលបត្រ, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រទី៦១

កាលដំបូង។ បន្តិចម្តងៗ ទីផ្សារភាគហ៊ុនបានវិវត្តខ្លួន ដោយនៅលើទីផ្សារនេះ មិនត្រឹមមានតែភាគហ៊ុនមួយមុខប៉ុណ្ណោះទេដែលត្រូវបានដាក់លក់ ប៉ុន្តែក៏មានឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតផងដែរដូចជា មូលបត្របំណុល ឧបករណ៍ដេរីវេទីវ ជាដើម។ ដោយសារតែហេតុនេះហើយ ទើបនៅប្រទេសមួយចំនួនធ្វើការផ្លាស់ប្តូរឈ្មោះទីផ្សារនេះទៅជាទីផ្សារមូលបត្រវិញ។[10]

## ១.៤. ប្រភេទនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រត្រូវបានបែងចែកជាពីរគឺ ទីផ្សារដំបូង (Primary Market) និងទីផ្សារបន្ទាប់ (Secondary Market)។

### ១.៤.១. ទីផ្សារដំបូង

ទីផ្សារដំបូង គឺជាកន្លែងដែលមូលបត្រត្រូវបានបោះចេញដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ (Issuer) លក់ទៅឱ្យសាធារណជន ដើម្បីទទួលបាននូវហិរញ្ញប្បទាន ឬមូលធនយកទៅវិនិយោគ។ នៅក្នុងដំណាក់កាលទីផ្សារដំបូងនេះហើយដែលក្រុមហ៊ុន ឬសហគ្រាស ធ្វើការប្រមូលទុនពីសាធារណជន ឬវិនិយោគិនដែលបានចូលរួមទិញមូលបត្រដែលបោះចេញដោយក្រុមហ៊ុន។ ដំណើរការដែលក្រុមហ៊ុនលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនេះ ត្រូវបានហៅថា «ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង» ឬជាភាសាអង់គ្លេសហៅថា «Initial Public Offering (IPO)»។ នៅក្នុងដំណាក់កាលនៃទីផ្សារដំបូង វិនិយោគិនអាចទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។ រាល់ការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅប្រទេសកម្ពុជា ត្រូវទទួលបានការអនុញ្ញាតជាមុនពីនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ដែលជានិយ័តករតែមួយគត់ក្នុងវិស័យមូលបត្រក្នុងប្រទេសកម្ពុជា។

### ១.៤.២. ទីផ្សារបន្ទាប់

ចំណែកទីផ្សារបន្ទាប់ គឺជាកន្លែងដែលមូលបត្រត្រូវបានជួញដូរបន្ត រវាងអ្នកទិញ និងអ្នកលក់ ដែលជាវិនិយោគិន មានន័យថាវិនិយោគិនដែលបានទិញមូលបត្ររួចក្នុងទីផ្សារដំបូងអាចលក់ចេញវិញបានទៅឱ្យវិនិយោគិនមួយផ្សេងទៀត។ ដោយទ្បែកប្រាក់ដែលបានមកពីសកម្មភាព ជួញដូរលើទីផ្សារបន្ទាប់ពីបានទៅលើអ្នកកាន់កាប់មូលបត្រ មិនមែនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រឡើយ ពោលគឺក្រុមហ៊ុនបោះផ្សាយលក់មូលបត្រមិនទទួលផលប្រយោជន៍សេដ្ឋកិច្ចពី ការជួញដូរលើទីផ្សារបន្ទាប់ឡើយ។ សម្រាប់ប្រទេសកម្ពុជា អ្នកដែលផ្តល់កន្លែងសម្រាប់ជួញដូរ មូលបត្រនៅលើទីផ្សារបន្ទាប់ គឺក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដែលជាប្រតិបត្តិករទីផ្សារ មូលបត្រទទួលបានការអនុញ្ញាតពីនិយ័តករបត្រកម្ពុជា។

[10] និយ័តករមូលបត្រកម្ពុជា, មគ្គុទេសក៍ស្តីពី ការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសារជារណៈនៅព្រះរាជាណាចក្រកម្ពុជា, (ភ្នំពេញ៖ គ.ម.ក, ២០១៧), ទំព័រទី៣

និយាយជារួម ទីផ្សារមូលបត្រមានសារៈសំខាន់ចំពោះសេដ្ឋកិច្ចជាតិព្រោះវាជាប្រភពទុនដែលជួយដល់ក្រុមហ៊ុន/សហគ្រាសដែលត្រូវការទុនបន្ថែម នោះនឹងធ្វើឱ្យមាននូវកំណើនសេដ្ឋកិច្ច នៅពេលដែលក្រុមហ៊ុន/សហគ្រាស កាន់តែរីកធំធាត់។ លើសពីនេះ ទីផ្សារមូលបត្រមិនត្រឹមតែឆ្លុះបញ្ចាំងពីស្ថានភាពទូទៅនៃសេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ប៉ុន្តែទីផ្សារនេះក៏ជួយសម្រួល និងពន្លឿនកំណើនសេដ្ឋកិច្ចជាតិផងដែរ។ គោលបំណងនៃទីផ្សារមូលបត្រគឺផ្សារភ្ជាប់រវាងតម្រូវការមូលនិធិ និងការផ្គត់ផ្គង់មូលនិធិក្នុងប្រព័ន្ធសេដ្ឋកិច្ច។ មូលនិធិដែលហូរចូលទីផ្សារមូលបត្រ គឺ កើតចេញពីរូបវន្តបុគ្គល និងស្ថាប័នហិរញ្ញវត្ថុនានាដែលមានទុន និងដែលមានបំណងវិនិយោគ ហើយទុនទាំងនោះនឹងត្រូវបានស្រូបយកដោយវិស័យឯកជន និងរដ្ឋាភិបាល ដើម្បីបម្រើឱ្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍគំនិតច្នៃប្រឌិតថ្មីៗជាដើមនៅក្នុងវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម ហើយការប្រើប្រាស់មូលនិធិទាំងនោះតាមរយៈវិស័យឯកជន និងរដ្ឋ នឹងធ្វើឱ្យសេដ្ឋកិច្ចជាតិមានកំណើន។[11]

## ១.៥. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ត្រូវបានបង្កើតឡើងស្របតាមទិសដៅរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុស៊ីជម្រៅ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ រហូតមកដល់ពេលនេះ អត្ថិភាពនៃអង្គ ៤ ជាសារវន្តដែលគាំទ្រដល់ដំណើរការនៃទីផ្សារមូលបត្រ ត្រូវបានកសាងជាបន្តបន្ទាប់រួមមាន[12]៖

- **ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure)**៖ សម្ដៅលើបទគតិយុត្តផ្សេងៗដូចជា ច្បាប់ បទប្បញ្ញត្តិ ដែលបានបង្កើតឡើងដោយនិយ័តករមូលបត្រ ដើម្បីគ្រប់គ្រងទីផ្សារមូលបត្រឱ្យមាន ប្រសិទ្ធភាព សមធម៌ តម្លាភាព និងសណ្ដាប់ធ្នាប់។ ជាមួយនេះផងដែរ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារមូលបត្រគឺសំដៅដល់ប្រព័ន្ធជួញដូរ រក្សាទុក និងជាត់ទាត់ និងទូទាត់មូលបត្រផងដែរ។ នាពេលបច្ចុប្បន្ននេះ មូលបត្រភាគច្រើនមិនមែនជាប្រភេទក្រដាសដូចកាលសម័យមុននោះទេ។ នៅកម្ពុជា និយ័តករមូលបត្រដែលបង្កើតបទដ្ឋានគតិយុត្តទីផ្សារមូលបត្រនោះគឺ និយ័តករមូលបត្រកម្ពុជា (ន.ម.ក) ហើយចំណែកឯប្រព័ន្ធជួញដូរ រក្សារទុក ជាត់ទាត់ និងទូទាត់មូលបត្រត្រូវផ្ដល់ដោយក្រុមហ៊ុនផ្សារមូលបត្រ (ផ.ម.ក)។
- **អន្តរការីមូលបត្រ (Intermediary)**៖ សម្ដៅដល់អង្គភាពរឺបុគ្គលដែលជាជំនួយនៅក្នុងដំណើរការទាំងអស់ ដែលទាក់ទងនឹងមូលបត្រ។ អន្តរការីមានតួនាទីជាអ្នកផ្ដល់ប្រឹក្សាយោបល់ណែនាំ និងជាជំនួយនៅក្នុងការបោះផ្សាយ និងទិញលក់មូលបត្រដល់ទាំងក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិនសាធារណៈ។ នៅក្នុងទីផ្សារមូលបត្រអន្តរការីដូចជា ពាណិជ្ជករមូលបត្រ អ្នកធានា ទិញមូលបត្រ ឈ្មោលជើងសារ និង ភ្នាក់ងារពាក់ពន្ធផ្សេងៗទៀត។ ប្រសិនបើគ្មានវត្តមាន អន្តរការីនោះទេនោះពុំមានការតភ្ជាប់ក្រុម-

[11] និយ័តករមូលបត្រកម្ពុជា, មគ្គុទេសក៏ស្ដីពី ការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសារធារណៈនៅព្រះរាជាណាចក្រកម្ពុជា, (ភ្នំពេញ៖ គ.ម.ក, ២០១៧), ទំព័រទី៤

[12] និយ័តករមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រ៖ តួអង្គសំខាន់ៗទាំង ៤ ក្នុងទីផ្សារមូលបត្រ (4Is) (លេខ VII ចេញផ្សាយឆ្នាំ២០១៦)

ហ៊ុនបោះផ្សាយទៅកាន់និយ័យតករ និងផ្សារមូលបត្រនោះឡើយ ហើយក៏គ្មានអ្នកទាក់ទាញវិនិយោគិនមូលបត្រជូនទៅឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រដែរ។

- **ក្រុមហ៊ុនបោះផ្សាយ (Issuer)**៖ គឺជាអង្គភាពបោះផ្សាយមូលបត្រនៃក្រុមហ៊ុនរបស់ខ្លួនដាក់លក់ឱ្យវិនិយោគិនសាធារណៈដើម្បីស្វែងរកដើមទុនបន្ថែមដល់ក្រុមហ៊ុន និងពង្រីកអាជីវកម្មរបស់ខ្លួន ដែលវាគឺជាតួអង្គដ៏សំខាន់មួយនៅក្នុងទីផ្សារមូលបត្រ ពីព្រោះ បើគ្មានវត្តមានរបស់ក្រុមហ៊ុនបោះផ្សាយទេ ក៏គ្មានមូលបត្រសម្រាប់លក់ដែរ។
- **វិនិយោគិន (Investor)**៖ សម្តៅទៅដល់អ្នកទិញ និងអ្នកលក់ រឺក៏អ្នកជួញដូរមូលបត្រក្នុងគោលបំណងដើម្បីស្វែងរកប្រាក់ចំណេញពីការវិនិយោគលើមូលបត្រនោះ វិនិយោគិនអាចជាសាធារណៈជនទូទៅ ឬក៏ជាស្ថាប័នដែលវិនិយោគិនទាំងនេះ ដើរតួយ៉ាងសំខាន់ដែរព្រោះបើពុំមានវិនិយោគិននោះទេការបោះផ្សាយលក់និងការជួញដូរមូលបត្រក៏ពុំទទួលបានជោគជ័យដែរ ។

## ១.៦. សារៈសំខាន់នៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រគឺ ដើរតួរយ៉ាងសំខាន់សម្រាប់ការបោះពុម្ពផ្សាយ សម្រាប់វិនិយោគិននានា ក៏ដូចជាសេដ្ឋកិច្ចទាំងមូល។ ដូចនេះហើយបានជាពិភពលោកយកចិត្តទុកដាក់ក្នុងការបង្កើត និងអភិវឌ្ឍន៍ក្នុងការបង្កើតប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានភាពខ្លាំងក្លា ក្នុងការពង្រឹងឱ្យកាន់តែមានភាពរឹងមាំ និងទិសដៅរក្សារនៅស្ថេរភាពក្នុងម៉ាក្រូសេដ្ឋកិច្ច។

ចាប់ពីសតវត្សទី២០មក ទីផ្សារភាគហ៊ុន បានក្លាយជាស្ថាប័នមួយក្នុងចំណោមស្ថាប័ន ដែលមានសក្តានុពលជាច្រើនផ្សេងទៀតសម្រាប់ការវិនិយោគ។ ការវិនិយោគទាំងឡាយតែងត្រូវប្រឈមនឹងហានិភ័យ រួមទាំងការវិនិយោគនៅក្នុងទីផ្សារភាគហ៊ុនដែលមានវិនិយោគិនខ្លះចំណេញ និងខ្លះទៀតខាតបង់ពីការវិនិយោគនេះ។ ក្រៅពីអាចប្រឈមនឹងហានិភ័យ វិនិយោគិនអាចទទួលបាននូវអត្ថប្រយោជន៍ពីការវិនិយោគក្នុងទីផ្សារភាគហ៊ុនមួយចំនួនផងដែរ។

### ១.៦.១. អត្ថប្រយោជន៍ទីផ្សារមូលបត្រសម្រាប់វិនិយោគិន

វិនិយោគអាចទទួលបានអត្ថប្រយោជន៍ជាច្រើនពីការជួញដូរមូលបត្រជាច្រើនដូចខាងក្រោម[13]៖

- **ទទួលបានភាគលាភ ដែលវិនិយោគិនចាត់ទុកថាជា “ប្រាក់ចំណូលអកម្ម” (Passive Income)**៖ ភាគហ៊ុនជាច្រើន ផ្តល់ឱ្យលោកអ្នកនូវប្រាក់ចំណូលក្នុងទម្រង់ជាភាគលាភ ដែលជាចំណែកនៃប្រាក់ចំណេញដែលក្រុមហ៊ុនរកបាន ហើយបង់ចំណែកនោះជូនវិនិយោគិនប្រចាំឆ្នាំ។ វិនិយោគិនអាចប្រើប្រាស់ភាគលាភ សម្រាប់ទុកចាយវាយនៅពេលចូលនិវត្តន៍ ឬយកទៅធ្វើការវិនិយោគបន្ត។

[13] និយ័តករមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រ៖ អត្ថប្រយោជន៍ទីផ្សារភាគហ៊ុនចំពោះវិនិយោគិន( លេខ VI ចេញផ្សាយឆ្នាំ២០១៦ )

- **ប្រាក់ចំណេញពីការទិញ-លក់ភាគហ៊ុន៖** អត្ថប្រយោជន៍ចម្បង ពីការវិនិយោគក្នុងទីផ្សារភាគហ៊ុន គឺឱកាសទទួលបានប្រាក់ចំណេញ។ ទីផ្សារភាគហ៊ុនមានទំនោរកើនឡើងនូវតម្លៃ បើទោះបីជាតម្លៃភាគហ៊ុននីមួយៗកើន ឬធ្លាក់ថ្លៃជារៀងរាល់ថ្ងៃក៏ដោយ។ ការវិនិយោគជាមួយក្រុមហ៊ុន ដែលមានស្ថេរភាព និងមានសក្តានុពល អាចនឹងធ្វើឱ្យវិនិយោគិនទទួលបានប្រាក់ចំណេញ ដោយទិញនៅពេលថ្លៃទាប ហើយលក់វិញ នៅពេលភាគហ៊ុនឡើងថ្លៃ។ មួយវិញទៀត ការវិនិយោគជាមួយភាគ-ហ៊ុនច្រើនផ្សេងៗគ្នា នឹងជួយបង្កើនទ្រព្យសម្បត្តិ តាមរយៈឥទ្ធិពលកំណើនពីវិស័យផ្សេងៗក្នុងសេដ្ឋ-កិច្ច បើទោះបីជាថ្លៃភាគហ៊ុនខ្លះដែលលោកអ្នកបានវិនិយោគធ្លាក់ថ្លៃក៏ដោយ។
- **ការធ្វើពិពិធកម្ម (Diversification)៖** អ្នកមានផែនការប្រើប្រាស់សាច់ប្រាក់សន្សំច្បាស់លាស់ តែងចំណាយយ៉ាងហោចណាស់ ១៥% ដើម្បីទិញភាគហ៊ុនធៀបនឹងការវិនិយោគសរុប។ សម្រាប់វិនិយោគិនដែលដាក់ប្រាក់ វិនិយោគច្រើនប្រភេទផ្សេងៗគ្នា ការវិនិយោគក្នុងទីផ្សារភាគហ៊ុនផ្តល់នូវអត្ថប្រយោជន៍សំខាន់មួយគឺ ពិពិធកម្ម។ ការវិនិយោគក្នុងទីផ្សារភាគហ៊ុន ប្រែប្រួលថ្លៃដោយមិនជាប់ទាក់ទងជាមួយការវិនិយោគផ្សេងទៀតដូចជា សញ្ញាបណ្ណ ឬអចលនទ្រព្យនោះទេ។ ដូច្នេះការវិនិយោគជាមួយទីផ្សារភាគហ៊ុន អាចជួយកាត់បន្ថយការខាតបង់បានខ្លះ ក្នុងករណីលោកអ្នកមានការខាតបង់ជាមួយការវិនិយោគផ្សេងទៀត។ ទោះបីជាភាគហ៊ុនមានហានិភ័យក៏ពិតមែន ភាគហ៊ុនអាចផ្តល់នូវប្រាក់ចំណេញមូលធនបានច្រើន និងឆាប់រហ័ស ព្រមទាំងជួយវិនិយោគិន ក្នុងការកាត់បន្ថយយុទ្ធសាស្ត្រវិនិយោគដែលមានភាពអភិរក្សពេក។
- **ភាពជាម្ចាស់កម្មសិទ្ធិ៖** ការទិញភាគហ៊ុន គឺមានន័យថាលោកអ្នកទទួលយកចំណែកនៃភាពជាម្ចាស់កម្មសិទ្ធិពីក្រុមហ៊ុនដែលបានលក់ភាគហ៊ុន ហើយវិនិយោគិនក៏មានសិទ្ធិទទួលបាននូវចំណែកនៃប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបានផងដែរ។ ភាគហ៊ុនិកមានសិទ្ធិបោះឆ្នោត និងមានចំណែកចូលរួមសម្រេចចិត្ត ក្នុងអាជីវកម្មរបស់ក្រុមហ៊ុនតាមសមាមាត្រនៃភាគហ៊ុនដែលខ្លួនកាន់-កាប់។ លើសពីនេះទៅទៀតសម្រាប់បុគ្គលិកដែលបានទិញ ឬកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដែលខ្លួនកំពុងបម្រើការងារឱ្យ អាចបង្ហាញពីភាពស្មោះត្រង់ និងការប្តេជ្ញាដើម្បីភាពជោគជ័យរយៈពេលវែងរបស់ខ្លួនឯងផ្ទាល់ និងក្រុមហ៊ុនផងដែរ។

### ១.៦.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ

#### ១.៦.២.១. ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង

នៅពេលគិតគូរអំពីគម្រោងពង្រីកអាជីវកម្មរបស់ខ្លួន សហគ្រាសខ្នាតតូច និងមធ្យមជានិច្ចកាលតែងជួបប្រទះបញ្ហាខ្វះខាតទុនសម្រាប់វិនិយោគ និងសម្រាប់ប្រើប្រាស់ជាទុនបង្វិល។ សហគ្រាសជាទូទៅមាន

ប្រភពហិរញ្ញប្បទានច្រើនពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ប៉ុន្តែភាគច្រើននៃប្រភពហិរញ្ញប្បទានទាំងនោះ ជាហិរញ្ញប្បទានរយៈពេលខ្លី ដែលអាចជារនាំងនៃការអភិវឌ្ឍផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុន។ ផ្ទុយទៅវិញ ជាមួយនឹងទីផ្សារមូលបត្រសហគ្រាសទាំងនេះអាចទទួលបានហិរញ្ញប្បទានរយៈពេលវែង តាមរយៈការបោះផ្សាយភាគហ៊ុននិងលក់ទៅឱ្យសាធារណៈជន ហើយទទួលបាននូវមូលនិធិសម្រាប់រួមចំណែកក្នុងការអនុវត្តផែនការអាជីវកម្មរយៈពេលវែងរបស់សហគ្រាស ដោយសហគ្រាសគ្រាន់តែទូទាត់ត្រលប់ទៅវិនិយោគិនវិញជាភាគលាភ ដែលអាស្រ័យតាមផលចំណេញជាក់ស្តែងរបស់សហគ្រាសនិងលទ្ធភាពក្នុងការដកសាច់ប្រាក់។

### ១.៦.២.២. ទទួលបានការលើកទឹកចិត្តពន្ធ

នេះគឺជាការលើកទឹកចិត្តសំខាន់មួយសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមដែលកំពុងសំឡឹងមើលការប្រមូលមូលនិធិតាមរយៈការបោះផ្សាយ និងលក់ភាគហ៊ុននៅលើផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនទាំងអស់ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅផ្សារមូលបត្រកម្ពុជា នឹងទទួលបានការកាត់បន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០% ក្នុងរយៈពេលបីឆ្នាំ។ ស្របពេលជាមួយគ្នានេះផងដែរ ក្រុមហ៊ុនក៏ទទួលបានការលើកលែងទាំងស្រុងចំពោះបំណុលពន្ធលើប្រាក់ចំណេញសម្រាប់រយៈពេល ១០ ឆ្នាំសារពើពន្ធកន្លងទៅ ដែលបានរកឃើញដោយស្នងការសវនកម្មឯករាជ្យ ក្រោយការធ្វើសវនកម្មពេញលេញរបស់អគ្គនាយកដ្ឋានពន្ធដារ។ បន្ថែមលើនេះទៀត ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ១% ប្រចាំខែ ត្រូវបានព្យួរជាបណ្តោះអាសន្នរយៈពេល៣ឆ្នាំ។

### ១.៦.២.៣. ទទួលបាននិរន្តរភាពអាជីវកម្មជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន

ការបង្កើតសហគ្រាសអាជីវកម្មមួយ គឺត្រូវប្រឈមនឹងបញ្ហាជាច្រើន ប៉ុន្តែការរក្សាអាជីវកម្មឱ្យមានចីរភាព គឺរឹតតែជាការងារដ៏លំបាកមួយ និងជាការប្រឈមដ៏ធំសម្រាប់ម្ចាស់អាជីវកម្ម។ សហគ្រាសខ្នាតតូច និងមធ្យមតែងតែជាកម្មវត្ថុនៃការបារម្ភនានាអំពីអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន។ យ៉ាងណាមិញនៅពេលដែលសហគ្រាសទាំងនេះ បានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឱ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ដែលនឹងមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើនេះទៀត ម្ចាស់អាជីវកម្មអាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រឹមត្រូវ ឬការបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផលអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងនឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឱ្យមានការរីកចំរើនប្រកបដោយនិរន្តរភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម នឹងអាចជួយដល់ការត្រៀមខ្លួនរបស់សហគ្រាសខ្នាតតូច និងមធ្យមក្នុងការប្រកួតប្រជែងជាមួយគូប្រកួតប្រជែងក្នុងតំបន់អាស៊ានដទៃទៀត។

**១.៦.២.៤. ការធ្វើឱ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងភាពមើលឃើញរបស់ក្រុមហ៊ុន**

ក្រុមហ៊ុនចុះបញ្ជីមួយ ជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស តាមរយៈប្រព័ន្ធព័ត៌មាន និងសាធារណៈជន ហើយកិច្ចប្រតិបត្តិការអាជីវកម្ម ឬហិរញ្ញវត្ថុតែងត្រូវបានផ្សព្វផ្សាយ តាមរយៈកាសែត និងទូរទស្សន៍ ព្រមទាំងត្រូវបានលើកឡើងទាំងក្នុង និងក្រៅប្រទេសផងដែរ។ ប្រការនេះអាច ជួយកែលម្អនូវរូបភាព និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនដែលអាចឱ្យសាធារណៈជនស្គាល់កាន់តែច្រើន អំពី ផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះ ក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមភាពប្រកួតប្រជែងរបស់ ខ្លួនចំពោះដៃគូប្រកួតប្រជែងដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ នៅក្នុងបរិបទនៃសេដ្ឋកិច្ចសកល-ភាវូបនីយកម្មដែលពោរពេញដោយការប្រកួតប្រជែង។

**១.៦.២.៥. ការត្រៀមខ្លួនជាមុនចំពោះបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល**

ក្រុមហ៊ុនទាំងអស់ កំពុងតែត្រូវបានឃ្លាំមើលដោយរាជរដ្ឋាភិបាល អំពីការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់ របស់ពួកគេដែលរួមទាំងការអនុវត្តពន្ធ ការកាន់បញ្ជីគណនី និងការធ្វើសវនកម្មជាដើម។ សេរីភាពដែលកំពុង ថមថយនេះ នឹងជម្រុញឱ្យចាប់ផ្តើមអនុវត្តឱ្យបានឆាប់នូវកាតព្វកិច្ចច្បាប់នានា និងការក្លាយខ្លួនជាក្រុមហ៊ុនចុះ បញ្ជីនៅក្នុងទីផ្សារមូលបត្រ។[14]

**១.៦.៣. អត្ថប្រយោជន៍ទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ**

- ទីផ្សារភាគហ៊ុនធ្វើឱ្យមានលំហូរសាច់ប្រាក់ពីក្រុមហ៊ុនដែលត្រូវការដើមទុន ទទួលបានមូលធន ដោយផ្ទាល់ពីវិនិយោគិន។
- ទីផ្សារភាគហ៊ុន ធ្វើឱ្យក្រុមហ៊ុនមានលទ្ធភាពពង្រីកអាជីកម្មរបស់ខ្លួន ដូចនេះផលិតកម្មក៏កើនឡើង ហើយប្រាក់ចំនូលក៏កាន់តែច្រើន មានន័យថាផលិតផលក្នុងស្រុកមានកំណើន ដែលចូលរួមចំនែក ដល់កំណើនសេដ្ឋកិច្ចជាតិ។
- វិស័យនានាក៏មានការរីកចម្រើន ដោយភាគហ៊ុនិកដើម អាចលក់ភាគហ៊ុនរបស់ខ្លួនក្នុងថ្លៃខ្ពស់ និង យកទៅវិនិយោគក្នុងវិស័យថ្មី។
- ចំណូលជាតិមានការកើនឡើង ព្រោះអាជីវកម្មរបស់ក្រុមហ៊ុនរីកចម្រើន នោះក្រុមហ៊ុននឹងត្រូវបង់ពន្ធ កាន់តែច្រើន។
- ទីផ្សារភាគហ៊ុន គឺជាសូចនាករមួយដែលអាចឱ្យយើងព្យាករណ៍ពីស្ថានភាពសេដ្ឋកិច្ចជាតិពេល អនាគត តាមរយៈការប្រែប្រួលសន្ទស្សន៍ផ្សារបច្ចុប្បន្ន។[15]

---

[14] ផ្សារមូលបត្រកម្ពុជា, អត្ថប្រយោជន៍ http://csx.com.kh/kh/product/blisting.jsp?MNCD=30101 ( ចូលថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២២ )

[15] ផ្សារហ៊ុន, អត្ថប្រយោជន៍នៃទីផ្សារភាគហ៊ុន, ២០១៨, https://phsarhun.com/news/45 ( ចូលថ្ងៃទី១៥ ខែមេសា ២០២២ )

# ជំពូកទី២

# ស្ថានភាពទូទៅរបស់

# និយ័តករមូលបត្រ

# ជំពូកទី២

# ស្ថានភាពទូទៅរបស់និយ័តករមូលបត្រ

## ២.១. ប្រវត្តិនិយ័តករមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ គណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក**) គឺជាអាជ្ញាធរគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមាន ឯកឧត្តម **ស៊ូ សុជាតិ** ជាអគ្គនាយក។ ក្នុងនាមជានិយតករមូលបត្រ គ.ម.ក. បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញ និងការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាតាមរយៈការបង្កើតច្បាប់ និងបទប្បញ្ញត្តិក៏ដូចជាគោលនយោបាយ និងគោលការណ៍ណែនាំនានា និងការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងមូលបត្រក្នុងគោលបំណងគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងកិច្ចគាំពារវិនិយោគិនសាធារណៈផងដែរ។ គ.ម.ក. ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិបរិក្សបណ្ឌិត **គាត ឈន់** អតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធាន គ.ម.ក.។ លុះដល់ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានតែងតាំងជាប្រធាន គ.ម.ក. រហូតដល់បច្ចុប្បន្ន។ លុះក្រោយមកគណៈកម្មការមូលបត្រកម្ពុជា បានធ្វើការផ្លាស់ប្តូរឈ្មោះទៅជា និយ័តករមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។[16]

## ២.២. នាមករណ៍ និងនិមិត្តសញ្ញារបស់និយ័តករមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា ដែលហៅកាត់ថា (គ.ម.ក) និងភាសាអង់គ្លេសថា Securities and Exchange Commission of Cambodia ហៅកាត់ថា (SECC) មាននិមិត្តសញ្ញាដូចខាងក្រោម៖

**រូបទី១ និមិត្តសញ្ញាចាស់របស់ គ.ម.ក.**

[16] ភ្នំពេញប៉ុស្តិ៍, ប្រធានបទទី១៖ តួនាទីគណៈកម្មការមូលបត្រកម្ពុជា, ២០២០, https://www.postkhmer.com/សេដ្ឋកិច្ច/ប្រធានបទទី-១៖-តួនាទីគណៈកម្មការមូលបត្រកម្ពុជា (ចូលថ្ងៃទី១៦ ខែមេសា ២០២២)

លុះក្រោយមកនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ និយ័តករមូលបត្រកម្ពុជា បានចេញសេចក្ដីជូនដំណឹងមួយស្ដីការការប្ដូរ "និមិត្តសញ្ញានិងត្រា" ថ្មីរបស់ខ្លួនបន្ទាប់ពីសមាហរណកម្មទៅក្នុងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនិងបទប្បញ្ញត្តិពាក់ព័ន្ធរួចមក។ យោងតាមសេចក្ដីជូនដំណឹងខាងលើនេះបានបញ្ជាក់ថា ដោយអនុលោមតាមច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនិងបទប្បញ្ញត្តិពាក់ព័ន្ធ។

## នាមករណ៍

នាមករណ៍របស់ក្រុមហ៊ុនមានឈ្មោះជាភាសាខ្មែរថា និយ័តករមូលបត្រកម្ពុជា ដែលហៅកាត់ថា (ន.ម.ក) និងភាសាអង់គ្លេសថា Securities and Exchange Regulator of Cambodia ហៅកាត់ថា (SERC)។

## និមិត្តសញ្ញាថ្មី

**រូបទី២ និមិត្តសញ្ញាថ្មីរបស់ ន.ម.ក.**

**១-រូបសញ្ញា**

- រូបហង្សពណ៌មាស
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្ដាំរំលេចស្រមោលពណ៌ប្រផេះ ។
- រូបរង្វង់ថាសដែលពាក់កណ្ដាលមានពណ៌មាស និងពាក់កណ្ដាលទៀតមានពណ៌ប្រផេះ ។
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "និយ័តករមូលបត្រកម្ពុជា" និងព័ទ្ធរង្វង់នៅផ្នែក ខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE REGULATOR OF CAMBODIA"។

**២-អត្ថន័យនៃរូបសញ្ញា**

- រូបហង្សមានពណ៌មាស តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះដែលតំណាងឱ្យភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជាប្រកបដោយប្រសិទ្ធភាពមានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើតំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**៣-មូលហេតុដែលជ្រើសរើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា**

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ ជាលើកដំបូងនៅលើប្រាក់ប្រាសាទក្នុងរជ្ជកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក **សំអាង ហង្ស** ដែលព្រះបាទអង្គឌួងបានបញ្ជូនឱ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឱ្យរូបិយវត្ថុខ្មែរមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ឱ្យធ្វើចរាចរក្នុងសេដ្ឋកិច្ច។
- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម សម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលការណ៍នេះត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយ ហើយមានប្រធានជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមកិត្តិបរិក្សបណ្ឌិត **គាត ឈន់**។

## ២.៣. ត្រារបស់និយ័តករមូលបត្រកម្ពុជា

**រូបទី៣ ត្រារបស់និយ័តករមូលបត្រកម្ពុជា**

ត្រារបស់និយ័តករមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្តាលមានសញ្ញាប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា «និយ័តករមូលបត្រកម្ពុជា»។[17]

## ២.៤. ចក្ខុវិស័យរបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជាហៅកាត់ថា ន.ម.ក ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច ។ ន.ម.ក មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។

## ២.៥. បេសកកម្មរបស់និយ័តករមូលបត្រកម្ពុជា

- បង្កើត និងរក្សាឱ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឱ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

[17] និយ័តករមូលបត្រកម្ពុជា, រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជា https://www.serc.gov.kh/khmer/m17.php?pn=1 ( ចូលថ្ងៃទី១៦ ខែមេសា ២០២២ )

- ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ច័យតាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ជំរុញឱ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៦. ទីតាំងរបស់និយ័តករមូលបត្រកម្ពុជា



**រូបទី៤ ទីស្តីការថ្មីរបស់និយ័តករមូលបត្រកម្ពុជា**

អាស័យដ្ឋាន៖ អគារ១៦៨F ផ្លូវលេខ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

អាចរកបានតាមរយៈ Google Map: https://goo.gl/maps/HW4hmBFh2hMR3v4S9

គេហទំព័រ: http://www.serc.gov.kh/

លេខទូរស័ព្ទទំនាក់ទំនង: (+855) 23 885 611

## ២.៧. រចនាសម្ព័ន្ធនៃការគ្រប់គ្រង




**រូបទី៥ រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា**

## ២.៨. មុខងាររបស់និយ័តករមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា មានតួនាទីដូចខាងក្រោម៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋ។
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ។
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ។
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ។
- ដើរតួរជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គល មានអាជ្ញាបណ្ណ ដែលប៉ះពាល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ។
- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោល នយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[18]

[18] ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/១០០៧/០២៨, ២០០៧, មាត្រាទី៧

# ជំពូកទី៣

# ស្ថានភាពទូទៅរបស់ផ្សារ

# មូលបត្រកម្ពុជា

# ជំពូកទី៣

# ស្ថានភាពទូទៅរបស់ផ្សារមូលបត្រកម្ពុជា

## ៣.១. ប្រវត្តិនៃទីផ្សារមូលបត្រ

ទស្សនៈសម័យទំនើប នៃការបង្កើតទីផ្សារភាគហ៊ុនបានចាប់ផ្តើមតាំងពីចុងសតវត្សទី ១៦ ។ ទីផ្សារភាគហ៊ុនត្រូវបានចាប់ផ្តើម នៅពេលបណ្តាប្រទេសនៅក្នុងទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតដែលមានដូចជាហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ។ ខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុប មានបំណងចាប់ផ្តើមអាជីវកម្មទំហំធំ ដែលទាមទារឱ្យមានចំនួនទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់មានប្រាក់ច្រើនសន្ធឹកសន្ធាប់សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំបានតែម្នាក់ឯងនោះទេ។ ជាលទ្ធផលវិនិយោគិនបានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងជាសហកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួន នៅក្នុងអាជីវកម្មមួយដែលមានទម្រង់ជាទុនរួម។ ក្រុមហ៊ុនរួមទុនដែលមានដើមកំណើតនៅប្រទេសហូឡង់ បានក្លាយជាគំរូអាជីវកម្មមួយសម្រាប់អាជីវកម្មដទៃ ដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ ១៦០២ ក្រុមហ៊ុន ឌី ឌាចហ៍ អីស ឥណ្ឌា (The Dutch East India Co.) បានបោះផ្សាយក្រដាសតំណាងភាគហ៊ុនជាលើកដំបូង។ ឧបករណ៍ដែលអាចជួញដូរបាននេះ អនុញ្ញាតឱ្យភាគហ៊ុនិកមានភាពងាយស្រួលក្នុងការទិញ-លក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួន ជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និងវិនិយោគិនដទៃទៀត។

គំនិតនេះទទួលបានជោគជ័យ ដោយការលក់ភាគហ៊ុន បានរីករាលដាលដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀតដូចជា ប្រទេសព័រទុយហ្គាល់ អេស្ប៉ាញ និងបារាំង។ នៅទីបំផុត ការអនុវត្តគំនិតនេះក៏បានរីករាលដាលដល់ចក្រភពអង់គ្លេស។ ឧស្សាហកម្មដទៃទៀតក្នុងកំឡុងពេលបដិវត្តន៍ឧស្សាហកម្ម បានចាប់ផ្តើមប្រើការលក់ភាគហ៊ុនជាវិធីដើម្បីប្រមូលមូលធន សម្រាប់ធ្វើអាជីវកម្ម។ ការហូរចូលនៃមូលធននេះ បានបន្តឱ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។

ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុន បានជំរុញឱ្យមានការបង្កើតទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផល ពាណិជ្ជករភាគហ៊ុនបានសម្រេចចិត្តទៅជួបគ្នានៅហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមក ហាងកាហ្វេនោះត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក ហើយប្រែឈ្មោះក្លាយជាទីផ្សារភាគ-ហ៊ុនដែលមានការរៀបចំ និងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ ១៧៧៣។ ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេ។ គំនិតនៃការរៀបចំបែបនេះ ក៏បានហូរចូលទៅក្នុង

ប្រទេសអាមេរិក ហើយក៏បានចាប់ផ្ដើមនៅទីក្រុង ភីឡា ឌែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ ១៧៩០។[19]

## ៣.២. ប្រវត្តិនៃទីផ្សារមូលបត្រកម្ពុជា

ដើម្បីធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍប្រទេស ដោយធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាមានការកើនឡើង នាខែវិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះហត្ថលេខាលើ អនុស្សរណៈយោគយល់ស្ដីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ដោយស្ថិតក្រោមគោលដៅក្នុងការជំរុញកំនើនសេដ្ឋកិច្ចតាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ សម្ដេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសបើកឱ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជានៅខែកញ្ញា ឆ្នាំ២០០៧។ ក្រោយមកនៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្ដីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ (ផ្សារមូលបត្រកម្ពុជា) ស្របតាមច្បាប់ស្ដីអំពីសហគ្រាសសាធារណៈ។ ផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា។ ផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូល-បត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រពី និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ស្របតាមច្បាប់ស្ដីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ផ្សារមូលបត្រកម្ពុជា ជាប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាននាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសការងារដែលមានភាពប្រសើរដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសក្រុមហ៊ុនដែលមានភាពល្អប្រសើរដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសក្រុមហ៊ុនក្នុងស្រុកដែលត្រូវការធនធានដើម្បីពង្រីកអាជីវកម្ម ព្រមជាមួយនឹងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិ។[20]

---

[19] និយ័តករមូលបត្រកម្ពុជា, ពុទ្ធិមូលបត្រះ ប្រវត្តទីផ្សារភាគហ៊ុន (ចេញផ្សាយប្រចាំសប្ដាហ៍ទី៤ ខែសីហា ឆ្នាំ២០១៦)

[20] ផ្សារមូលបត្រកម្ពុជា, ប្រវត្តិ ផមក, http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលថ្ងៃទី១៨ ខែមេសា ២០២២)

## ៣.៣. នាមករណ៍ និងនិមិត្តសញ្ញារបស់ផ្សារមូលបត្រកម្ពុជា

### នាមករណ៍

នាមករណ៍របស់ក្រុមហ៊ុនមាននាមជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលហៅកាត់ថា (ផ.ម.ក) និងឈ្មោះជាភាសាអង់គ្លេសថា Cambodia Securities Exchange ដែលហៅកាត់ថា (CSX)។

### និមិត្តសញ្ញា

**រូបទី៦ និមិត្តសញ្ញាផ្សារមូលបត្រកម្ពុជា**

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានអត្តសញ្ញាណដូចខាងក្រោម៖ ផ្នែកខាងលើមានសរសេរអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងរបស់ក្រុមហ៊ុន។ រីឯនៅផ្នែកខាងស្តាំមានរូបហង្សពណ៌មាសមួយ ដែលឈរបែរមុខទៅខាងស្តាំ។ ចំនែកនៅពីក្រោមអក្សរផ្នែកខាងឆ្វេងមានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រជាអក្សរកាត់ភាសាអង់គ្លេស ដែលមានពណ៌ខៀវដូចនឹងឈ្មោះខាងលើដែរ។

## ៣.៤. ចក្ខុវិស័យរបស់ផ្សារមូលបត្រកម្ពុជា

ដើម្បីធ្វើឱ្យក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានដំណើរការល្អនិងការរីកចម្រើននៅលើមាគ៌ាមួយដ៏ត្រឹមត្រូវ ក្រុមហ៊ុនបានកំណត់គោលការណ៍យ៉ាងច្បាស់លាស់ទៅលើចក្ខុវិស័យរបស់ខ្លួនគឺ ដើម្បីកសាងនូវ «**មហាវិថី**» ហិរញ្ញវត្ថុសម្រាប់កម្ពុជា ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការជួញដូរមូលបត្រ។

## ៣.៥. បេសកម្មក្រុមហ៊ុនមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រុមហ៊ុនផ្សារមូលបត្របានដាក់ចេញនូវបេសកម្មមួយចំនួនដូចជា៖

- ជួយសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- បង្កើត និងបង្កើននូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- បង្កើតនូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួម ទីផ្សារទាំងអស់

- ជួយដាក់ឱ្យដំណើរការនូវ សហគ្រាសសាធារណៈមួយដែលមានស្វ័យចីរភាព ក្រោមមគ្គុទេសដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។[21]

## ៣.៦. ទីតាំងរបស់ផ្សារមូលបត្រកម្ពុជា




**រូបទី៧ ទីតាំងផ្សារមូលបត្រកម្ពុជា**

អាស័យដ្ឋាន៖ អគារ ផ.ម.ក ផ្លូវលេខ១០៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

អាចរកបានតាមរយៈ Google Map: https://maps.app.goo.gl/4TPPq3LCXeW613zS6

គេហទំព័រ: www.csx.com.kh

លេខទូរស័ព្ទទំនាក់ទំនង: (+855) 23 958 888

[21] ផ្សារមូលបត្រកម្ពុជា, ចក្ខុវិស័យ & បេសកកម្ម http://csx.com.kh/kh/about/mission.jsp?MNCD=1020 (ចូលថ្ងៃទី១៨ ខែមេសា ២០២២)

## ៣.៧. រចនាសម្ព័ន្ធនៃការគ្រប់គ្រង




**រូបទី៨ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ផ្សារមូលបត្រកម្ពុជា**

## ៣.៨. តួនាទីទីផ្សារមូលបត្រក្នុងសេដ្ឋកិច្ច

ទីផ្សារមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងការឆ្លើយតប ទៅនឹងតម្រូវការនេះតាមរយៈការកៀរគរមូលធន ដែលចាំបាច់សម្រាប់នវានុវត្តន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សហគ្រាស ធំៗ និងសហគ្រាសធុនតូច និងមធ្យមប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ផ្សារមូលបត្របានជួយជំរុញដល់កំណើនសេដ្ឋកិច្ចដូចជា[22]៖

- ផ្សារភ្ជាប់អ្នកផ្គត់ផ្គង់ និងអ្នកមានតម្រូវការមូលធន៖ ទីផ្សារមូលបត្រអនុញ្ញាតឱ្យមូលធនហូរចេញពីអ្នកផ្គត់ផ្គង់ ទៅកាន់អ្នកដែលមានតម្រូវការ។ នេះមានន័យថា អ្នកមានតម្រូវការហិរញ្ញប្បទានដូចជា ក្រុមហ៊ុន និងសាជីវកម្មអាចប្រើប្រាស់មូលធនដែលបានពីប្រាក់សន្សំរបស់វិនិយោគិនបុគ្គល ដើម្បីវិនិយោគលើនវានុវត្តន៍ហេដ្ឋារចនាសម្ព័ន្ធ និងការផលិតទំនិញ និងសេវាកម្ម ដែលនេះជាហេតុបណ្តាលឱ្យមានការកើនឡើងនៃផលិតភាពនៅក្នុងសេដ្ឋកិច្ច នាំឱ្យមានការងារកាន់តែច្រើន ការប្រើប្រាស់ទំនិញ និងសេវាកម្មកាន់តែច្រើន ដែលនាំឱ្យសកម្មភាពសេដ្ឋកិច្ចឈានទៅរកកំណើន និងការអភិវឌ្ឍ។
- ជំរុញឱ្យមានការវិនិយោគ និងសន្សំ៖ ទីផ្សារមូលបត្រលើកទឹកចិត្តឱ្យមានការសន្សំរយៈពេលវែងក្នុងចំណោមសាធារណជន និងវិនិយោគិនបុគ្គល។ វាក៏ជួយសម្រួលដល់ប្រសិទ្ធភាពមុខងាររបស់ប្រព័ន្ធធនាគារ ដោយអាចធ្វើការផ្គូផ្គងដោយផ្ទាល់រវាងវិនិយោគិននឹងការវិនិយោគរយៈពេលវែង ។ ការបង្កើនការវិនិយោគតាមរយៈការរួមទុនលើក្រុមហ៊ុនផលិតកម្ម និងសេវាកម្មកាន់តែច្រើន អនុញ្ញាតឱ្យសាធារណជនទទួលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច លើកកម្ពស់កម្រិតជីវភាព និងបង្កើតបានឱកាសវិនិយោគផ្សេងៗដែលទាំងអស់នេះសុទ្ធសឹងតែជាកត្តានាំមកនូវកំណើនសេដ្ឋកិច្ច។

[22] ប៉ុស្ត៍មូលបត្រ៖ ចំណេះដឹងមូលដ្ឋាន, តួនាទីរបស់ទីផ្សារមូលបត្រក្នុងការជំរុញកំណើនសេដ្ឋកិច្ច, (ចេញផ្សាយថ្ងៃទី១ មិថុនា ២០២០)

- ផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺជាលក្ខខណ្ឌចាំបាច់សម្រាប់កំណើន និងការអភិវឌ្ឍរយៈពេលវែងប្រកបដោយចីរភាព។ ទីផ្សារមូលបត្រ គឺជាច្រកហិរញ្ញប្បទានដ៏សមស្រប សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋ-កិច្ចសង្គមតាមរយៈការបំពេញតម្រូវការសំខាន់ៗដូចជា ការស្ថាបនាផ្លូវថ្នល់ ប្រព័ន្ធលូ ការដឹកជញ្ជូនសាធារណៈ ថាមពល លំនៅឋាន និងប្រព័ន្ធទូរគមនាគមន៍ជាដើម។
- បែងចែកធនធានមូលធនឱ្យមានប្រសិទ្ធភាព៖ ទីផ្សារមូលបត្រជំរុញឱ្យមានការបែងចែកធនធានមូលធនឱ្យមានប្រសិទ្ធភាពតាមរយៈការផ្តល់នូវផលិតផលវិនិយោគច្រើនប្រភេទដែលមានលក្ខណៈផ្សេងៗគ្នា ដែលទាំងនេះ អនុញ្ញាតឱ្យវិនិយោគិនបែងចែកធនធានទៅលើការវិនិយោគយ៉ាងមានប្រសិទ្ធភាពទៅតាមបុគ្គលិកលក្ខណៈនៃវិនិយោគិននីមួយៗក្នុងការហ៊ានទទួលយកហានិភ័យ និងប្រាក់ចំណេញ។
- ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម៖ យោងតាមក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សហគ្រាសធុនតូច និងមធ្យមបានចូលរួមចំណែក ៥៨% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) និងបង្កើតការងារប្រហែល ៧០% នៃការងារសរុបនៅកម្ពុជាដែលផ្តល់នូវប្រាក់ចំណូលសម្រាប់បុគ្គលដែលមានចំណូលទាប និងមធ្យម ជំរុញកំណើនសេដ្ឋកិច្ច និងស្ថិរភាពសង្គម។ ទីផ្សារមូលបត្រដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រដល់កំណើននេះ តាមរយៈការផ្តល់នូវហិរញ្ញប្បទានក្នុងបរិយាកាសមួយអំណោយផល ដល់សហគ្រាសធុនតូច និងមធ្យម ដូចជាកាត់បន្ថយចំណាយ និងបន្ទុកផ្សេងៗ ក្នុងការទទួលបានប្រភពទុន ដែលចាំបាច់សម្រាប់ការពង្រីកអាជីវកម្មរបស់ពួកគេ។

# ជំពូកទី៤

# ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

# ជំពូកទី៤

# ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

## ៤.១. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO)

IPO (Initial Public Offering) គឺជាការលក់ភាគហ៊ុនជាលើកដំបូង ឬបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតទៅកាន់សាធារណៈជន។ ក្រុមហ៊ុនធានាទិញមូលបត្រ បានជួយផ្ដល់ជាជំនួយដល់ដំណើរការប្រតិបត្តិការ IPO ដោយក្រុមហ៊ុនទាំងនោះបានជួយកំណត់ពីប្រភេទមូលបត្រដែលត្រូវបោះផ្សាយលក់ ថ្លៃសម្រាប់សំណើលក់ល្អបំផុត និងពេលវេលាដែលត្រូវឡើងទីផ្សារមូលបត្រ។

ក្រុមហ៊ុនត្រូវការធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដើម្បី[23]៖

- ស្វែងរកមូលធនដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន
- ក្រុមហ៊ុនអាចប្រកបបរអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព
- ជំរុញឱ្យសាធារណៈជនស្គាល់ពីក្រុមហ៊ុន
- ទទួលបាននូវភាពងាយស្រួលក្នុងការស្វែងរកហិរញ្ញប្បទាន និងកាលានុវត្តភាពនៃការធ្វើហិរញ្ញប្បទាន
- ការលើកទឹកចិត្តផ្នែកពន្ធដារ
- ក្លាយជាក្រុមហ៊ុនមហាជន និងមានភាពច្បាស់លាស់
- ការបង្កើតសន្ទីយភាពមូលបត្រនៅលើទីផ្សារ
- ការពង្រីកមូលដ្ឋានភាគហ៊ុនិក
- រក្សាបុគ្គលិកខ្លួន និងទាក់ទាញអ្នកមានសមត្ថភាព
- បង្កើនកម្លាំងចិត្តរបស់បុគ្គលិក និងផលិតភាព។

## ៤.២. តួអង្គសំខាន់ៗក្នុងដំណើរការនៃការធ្វើ IPO

តួអង្គសំខាន់ៗដែលចូលរួម ក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសារធារណៈលើកដំបូងមានដូចជា និយ័តករមូលបត្រកម្ពុជា ផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងវិនិយោគិន។ គ្រប់តួអង្គទាំងអស់សុទ្ធតែមានតួនាទីសំខាន់រៀងៗខ្លួន ក្នុងដំណើរប្រតិបត្តិការ IPO ដែលមិនអាចខ្វះបាន។

[23] ហោងច័ន្ទបូលីន, កិច្ចដំណើរការទីផ្សារបន្ទាប់, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រទី៦-៩

#### ៤.២.១. និយ័តករមូលបត្រកម្ពុជា (Securities Regular)

និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារអ្នកវិនិ-យោគមូលបត្រ ព្រមទាំងធានាឱ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ និយ័តករមូលបត្រមានសមត្ថកិច្ច និងសិទ្ធិអំណាចពេញលេញក្នុងការរៀបចំនូវបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធវិស័យមូលបត្រ។

#### ៤.២.២. ផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាហៅកាត់ថា ផ.ម.ក ឬ CSX គឺជាសហគ្រាសសាធារណៈដែលត្រូវបានបង្កើតឡើងដើម្បីរៀបចំ និងដាក់ឱ្យដំណើរការទីផ្សារមូលបត្រនៅកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រនៅកម្ពុជាបានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករ ប្រតិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សា ទុកមូលបត្រ។

##### ៤.២.២.១. ប្រតិបត្តិករទីផ្សារមូលបត្រ

ប្រតិបត្តិករទីផ្សារមូលបត្រ សំដៅទៅដល់បុគ្គលដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រដូចជាការផ្តល់សេវាសម្រាប់សម្រួលដល់អ្នកចូលរួមក្នុងទីផ្សារ (ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ពន្ធ័នឹងមូលបត្រ) ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីឱ្យអ្នកចូលរួមក្នុងទីផ្សារអាចទទួលបាននូវបន្សុីលើប្រតិបត្តិការបញ្ជាទិញឬលក់មូលបត្ររបស់ខ្លួនតាមរយៈទីកន្លែង ប្រព័ន្ធ ឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិក។

##### ៤.២.២.២. ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់មូលបត្រ សំដៅទៅដល់បុគ្គលដែលធ្វើប្រតិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ដើម្បីធានាបានថាអ្នកលក់នឹងទទួលបានការទូទាត់ ហើយអ្នកទិញនឹងទទួលបានភាពជាម្ចាស់កម្មសិទ្ធិទៅតាមចំនួនមូលបត្រដែលមានជួញដូរ។

##### ៤.២.២.៣. ប្រតិបត្តិការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅកន្លែងមួយសម្រាប់ដាក់ផ្ញើរមូលបត្រដែលបានជួញដូររួចរវាងវិនិយោគិន និងវិនិយោគិន។ រាល់មូលបត្រទាំងអស់ ដែលបានដាក់ផ្ញើរត្រូវបានគេរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិចយ៉ាងមានសុវត្ថិភាព។

#### ៤.២.៣. ក្រុមហ៊ុនមូលបត្រ ( Securities Firms)

##### ៤.២.៣.១. អាជីវកម្មធានាទិញមូលបត្រ (Securities Underwriting)

ក្រុមហ៊ុនធានាទិញមូលបត្រដើរតួយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួល និងសហការជាមួយសមាជិកក្រុមកាងារបោះផ្សាយលក់មូលបត្រផ្សេងទៀត ក្នុងការរៀបចំឯកសារពាក់ព័ន្ធ និងត្រួតពិនិត្យដំណើរការ

ចុះបញ្ជីទាំងស្រុង រួមទាំងដំណាក់កាលនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។ នៅក្នុងការធ្វើអាជីវកម្ម ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្ដល់សេវាកម្មមួយចំនួនដល់អ្នកវិនិយោគសាធារណៈដូចជា៖

- ផ្ដល់ប្រឹក្សាសំខាន់លើ ការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជាដាក់តម្លៃមូលបត្រ (Pricing) ការកំណត់ទំហំទឹកប្រាក់ (Issue Amount) និងចំនួនមូលបត្រនៃសំណើបោះផ្សាយលក់មូលបត្រ និងកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាដើម។
- ក្រុមហ៊ុនធានាទិញមូលបត្រទិញមូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ក្នុងគោលដៅចែកចាយ ឬលក់បន្ត។
- ទិញមូលបត្រដែលមិនលក់មិនអស់ ឬតាមការព្រមព្រៀងនៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- ជួយរៀបចំ ត្រួតពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់ និងបញ្ជាក់លើឯកសារផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងសំណើរលក់មូលបត្រជាសាធារណៈ ឬសំណើរលក់មូលបត្រឯកជន និងចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ឬចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។[24]

យោងតាមគេហទំព័រ និយ័តករមូលបត្រកម្ពុជា គិតត្រឹមខែមេសា ឆ្នាំ២០២២ ក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក. មានចំនួន៧ដូចជា[25]៖

- យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី Yuanta Securities (Cambodia) Plc.
- អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា)ម.ក RHB Securities (Cambodia) PLC.
- កាណា ស៊ីឃ្យូរីធី អិលធីឌី Cana Securities Ltd.
- កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី Campu Securities Plc.
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី SBI Royal Securities Plc.
- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី Phnom Penh Securities Plc.
- ខេមបូឌា ស៊ីឃ្យូរីធី ម.ក Cambodia Securities Plc.

[24] ហេងច័ន្ទបូលីន, កិច្ចដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា, មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ទំព័រ៤០

[25] ផ្សារមូលបត្រកម្ពុជា, បញ្ជីឈ្មោះក្រុមហ៊ុន http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលថ្ងៃទី ២៥ ខែមេសា ២០២២)

**៤.២.៣.២. អាជីវកម្មជួញដូរមូលបត្រ (Securities Dealing)**

អាជីវកម្មជួញដូរមូលបត្រ គឺជាការជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងហានិភ័យដោយខ្លួនឯង។ ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រធ្វើជាក្រុមហ៊ុន ជួញដូរមូលបត្រអាចធ្វើសកម្មភាពអាជីវកម្មមូលបត្រដូចជា អាជីវកម្មជួញដូរមូលបត្រ អាជីវកម្មជើងសាមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ ក្រុមហ៊ុនជួញដូរមូលបត្រនៅកម្ពុជាមានចំនួន២គឺៈ

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ACLEDA Securities Plc.
- ហ្គោលដេន ហ្វ៉រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី Golden Fortune (Cambodia) Securities Plc.

**៤.២.៣.៣. អាជីវកម្មជើងសាមូលបត្រ (Securities Brokerage)**

អាជីវកម្មជើងសាមូលបត្រ គឺជាការទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួនដោយទទួលបាននូវកម្រៃជើងសា។ ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មជើងសាមូលបត្រអាចធ្វើអាជីកម្មដូចជា អាជីវកម្មជើងសាមូលបត្រ និងអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ ក្រុមហ៊ុនជើងសារមូលបត្រនៅកម្ពុជាមានចំនួន៥គឺៈ

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ACLEDA Securities Plc.
- ខេប ស៊ីឃ្យូរីធី លីមីធីត CAB Securities Limited.
- ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ឯ.ក Cambodia-Vietnam Securities Co., Ltd.
- ភីភី លីង ស៊ីឃ្យូរីធី ឯ.ក PP Link Securities Co., Ltd
- ហ្គោលដេន ហ្វ៉រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី Golden Fortune (Cambodia) Securities Plc.

**៤.២.៣.៤. អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ (Investment Advisory)**

អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ គឺការផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រ ការរៀបចំផែនការហិរញ្ញវត្ថុ ការវិភាគមូលបត្រ ស្ថានភាពទីផ្សារមូលបត្រ ផែនការវិនិយោគលើមូលបត្រ តាមតម្រូវការ និងគោលដៅរបស់អតិថិជន។ ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនដល់វិនិយោគិនសាធារណៈ។ ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មផ្តល់ប្រឹក្សា វិនិយោគអាចធ្វើអាជីកម្មផ្តល់ប្រឹក្សាវិនិយោគប៉ុណ្ណោះ។ ក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគនៅកម្ពុជាមានចំនួន២គឺៈ

- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី Phnom Penh Securities Plc.
- ខេមបូឌា ស៊ីឃ្យូរីធី ម.ក Cambodia Securities Plc.

### ៤.២.៤. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឬនីតិបុគ្គលប្រតិស្រុត ដែលស្នើសុំឬបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជាក្នុងការធ្វើប្រតិបត្តិការបោះផ្សាយលក់មូលបត្រ។

យោងតាមគេហទំព័រ ផ្សារមូលបត្រកម្ពុជា គិតត្រឹមខែមេសា ឆ្នាំ២០២២ ក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិមានចំនួន ៩ ដូចដែលបានរៀបរាប់នៅខាងក្រោម។

#### ក. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើងជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគឺជាសហគ្រាសសាធារណៈមួយរបស់ប្រទេសកម្ពុជាដែល ផ្តល់សេវាកម្មទឹកស្អាត ការផ្គត់ផ្គង់ទឹកស្អាត និងការចែកចាយទឹកស្អាត។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានចុះបញ្ជីជាផ្លូវការនៅ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង ១៥% នៃចំនួនភាគហ៊ុនធម្មតាសរុប ។[26]

**រូបទី៩៖ និមិត្តសញ្ញា PPWSA**

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនធម្មតា |
| ភាគហ៊ុនបោះផ្សាយ | ១៣.០៤៥.៩៧៥ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី២៩/០២/២០១២ ដល់ ថ្ងៃទី១៣/០៣/២០១២ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ពី ៤.០៥០រៀល ដល់ ៦.៣៥០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៩/០៣/២០១២ ដល់ ថ្ងៃទី០៤/០៤២០១២ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៦.៣០០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | គុងយ៉ាង ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី |

**តារាងទី១៖ លទ្ធផលនៃ IPO របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

[26] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីក្រុមហ៊ុនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000010004 (ចូលថ្ងៃទី២៨ ខែមេសា ២០២២)

### ខ. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធើណេសិនណល

រូបទី១០៖ និមិត្តសញ្ញា GTI

ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ីនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិតសម្លៀកបំពាក់ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ ក្រុមហ៊ុន ហ្គ្រេនធ្វីន បានទិញយកក្រុមហ៊ុន QMI Industrial Co., Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយក្នុង ចំណោមរោងចក្រកាត់ដេរធំៗដំបូងបង្អស់ដែលបានធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុង កំឡុងទសវត្សរ៍ឆ្នាំ ១៩៩០។ ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃ ផលិតផលរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីនរួមមានម៉ាកសម្លៀកបំពាក់កីឡាល្បីៗដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohl’s, Nautica, North Face, Russell Athletic។ ក្រុមហ៊ុន ហ្គ្រេនធ្វីន បានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤។[27]

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល ភីអិលស៊ី |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនធម្មតា |
| ភាគហ៊ុនបោះផ្សាយ | ៨.០០០.០០០ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី១៧ ដល់ ថ្ងៃទី២៨/០៣/២០១៤ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ៧.៤០០ រៀល ដល់ ១៤.០០០ រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២ ដល់ ថ្ងៃទី២៨/០៥/២០១៤ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៩.៦៤០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី |

**តារាងទី២៖ លទ្ធផលនៃ IPO របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល ភីអិលស៊ី**

[27] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000020003 (ចូលថ្ងៃទី២៨ ខែមេសា ២០២២)

### គ. កំពង់ផែស្វយ័តភ្នំពេញ

រូបទី១១៖ និមិត្តសញ្ញា PPAP

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) គឺប្រតិបត្តិករ មួយក្នុងចំណោមប្រតិបត្តិករកំពង់ផែកុងតឺន័រអន្តរជាតិ២នៅកម្ពុជា ហើយក៏ជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាអាជ្ញាធរគ្រប់គ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ ។ ក្នុងនាមជាប្រតិបត្តិករផែ ក.ស.ភ. ផ្តល់សេវាកម្មលើកដាក់ក្រោមដងយោង លើកដាក់លើទីលាន ឃ្លាំងស្តុកទុកទំនិញ កណ្តូជាកិច្ច ទីលានស្តុកទុកសំបកកុងតឺន័រពីរៀបទំនិញ ទូកុងតឺន័រត្រជាក់ វាស់ស្ទង់និងបូមស្ពារ ជួសជុល និងថែទាំកុងតឺន័រ ប្រមូលផ្តុំ/ចែកចាយទំនិញ និងសេវារថយន្តដឹកជញ្ជូនក្រៅចំណតផែ។ មណ្ឌលអាជីវកម្មផែមានប្រវែង ១៦០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំទៅដល់ព្រំប្រទល់កម្ពុជា-វៀតណាម នៅឯក្អមសំណ។ នៅឆ្នាំ២០១៥ ក.ស.ភ. ទទួលបានសិទ្ធ ផ្តាច់មុខជាប្រតិបត្តិករកំពង់ផែនៅក្នុងមណ្ឌលអាជីវកម្មផែ។ ក្នុងមណ្ឌលអាជីវកម្មផែនេះ ក.ស.ភ. បាននិងកំពុងប្រតិបត្តិការនៅទីតាំងនៃចំណតផែចំនួន ៥ គឺ ១-ចំណតផែកុងតឺន័រ LM១៧ ២-ចំណតផែពហុបំណង TS៣ ៣-ចំណតផែពហុបំណង KM៦ ៤-ចំណតផែទន្លេបិទ UM២ និង ៥-ចំណតផែអ្នកដំណើរ និងទេសចរ TS១។ ក.ស.ភ បានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥។[28]

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | កំពង់ផែស្វយ័តភ្នំពេញ |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៤.១៣៦.៨៧៣ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី១៩ ដល់ ថ្ងៃទី២២/១០/២០១៥ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ៤.៤០៥ រៀល ដល់ ៦.៣២០ រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី១២ ដល់ ថ្ងៃទី១៧/១១/២០១៥ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៥.១២០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | យាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី |

**តារាងទី៣៖ លទ្ធផលនៃ IPO របស់កំពង់ផែស្វយ័តភ្នំពេញ**

[28] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីកំពង់ផែស្វយ័តភ្នំពេញ http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000040001 (ចូលថ្ងៃទី២៨ ខែមេសា ២០២២)

### ឃ. ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត

រូបទី១២៖ និមិត្តសញ្ញា PPSP

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (”PPSEZ”) និង ប៉ោយ-ប៉ែត ភីភី អេសអ៊ីហ្សិត (“Poipet PPSEZ”) ។ នាថ្ងៃទី១៩ មេសា ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីក្លាយខ្លួនជា អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ ហើយបច្ចុប្បន្ននេះ ក្រុមហ៊ុននេះជាតំបន់សេដ្ឋកិច្ចពិសេសដែលកំពុងធ្វើប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ ឬជួល។ ក្រុមហ៊ុនក៏មានផ្តត់ផ្គង់សេវាកម្មដែលពាក់ព័ន្ធព្រមជាមួយបរិក្ខារចាំបាច់នានា នៅក្នុងបរិវេណ PPSEZ ដែលរួមមាន ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត សេវាជួល ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ និងជំនួយកិច្ចការរដ្ឋបាល ប្រព្រឹត្តិកម្មទឹកសំអុយ និងសេវាកម្មដទៃទៀត។ ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី បានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦។[29]

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ១១.៥៧៥.០០០ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី១៨ ដល់ ថ្ងៃទី២៥/០៤/២០១៦ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ២.៨០០រៀល ដល់ ៤.០០០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី៩ ដល់ ថ្ងៃទី១២/០៥/២០១៦ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ២.៨៦០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី កម្ពុ ស៊ីឃ្យួរីធី និងកាណា ស៊ីឃ្យួរីធី |

**តារាងទី៤៖ លទ្ធផលនៃ IPO របស់ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត**

[29] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000050000 (ចូលថ្ងៃទី២៨ ខែមេសា ២០២២)

## ខ. កំពង់ផែស្វយ័តក្រុងព្រះសីហនុ

រូបទី១៣៖ និមិត្តសញ្ញា PAS

កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាក្រុមហ៊ុនរដ្ឋដែលបានបង្កើតឡើងដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើការងារៈ កណ្តាធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភារដល់នាវា, លើកដាក់ ផ្ទេរ ផ្ទុកទំនិញ, ស្តុកទំនិញនៅឃ្លាំង និងទីលាន ព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស ក៏កំពុងផ្តល់សេវាកម្មផ្សេងទៀតដូចជា សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចជាជួលឃ្លាំងនិងថែរក្សាទំនិញ លើកដាក់ និងដឹកជញ្ជូនទំនិញ រួមទាំងសេវាសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ ក.ស.ស ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ហិចតា នៅខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះរួមមានបណ្តាញផ្លូវគោក (ផ្លូវជាតិលេខ ៣ និងលេខ ៤), បណ្តាញផ្លូវរថភ្លើង (តភ្ជាប់ទៅរាជធានីភ្នំពេញ និងខេត្តកំពត) និងបណ្តាញផ្លូវអាកាស (តភ្ជាប់ទៅខេត្តសៀមរាប និងរាជធានីភ្នំពេញ)។ កំពង់ផែស្វយ័តក្រុងព្រះ-សីហនុបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧។[30]

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ២១.៤៤២.៩៩២ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី២៥/០៤ ដល់ ថ្ងៃទី០២/០៥/២០១៧ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ៣.៥២០រៀល ដល់ ៥.១៨០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី១៧ ដល់ ថ្ងៃទី២២/០៥/២០១៧ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៥.០៤០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី |

**តារាងទី៥៖ លទ្ធផលនៃ IPO របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

[30] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីកំពង់ផែស្វយ័តក្រុងព្រះសីហនុ http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000060009 (ចូលថ្ងៃទី០១ ខែឧសភា ២០២២)

### ច. ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ ដែលស្ថិតក្រោមគម្រោងអង្គការពលកម្មអន្តរជាតិក្នុងយុគសម័យក្រោយ សង្គ្រាមនៅកម្ពុជា។ ជាច្រើនឆ្នាំមកនេះ ធនាគារ អេស៊ីលីដា បានឆ្លងកាត់ការផ្លាស់ប្តូរជាច្រើន។ បច្ចុប្បន្ន ធនាគារ អេស៊ីលីដា មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ ហើយគឺជាធនាគារឈានមុខ និងធំជាងគេផ្នែកឥណទានដុល និងបណ្តាញចែកចាញគ្រប់ខេត្ត-ក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អេស៊ីលីដា ទទួលប្រាក់បញ្ញើពីអតិថិជន និងផ្តល់ដល់អតិថិជននូវផលិតផលឥណទានច្រើនប្រភេទ ព្រមទាំងសេវាហិរញ្ញវត្ថុផ្សេងៗទៀត។ ដូចជាការផ្ទេរប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ ហិរញ្ញប្បទានពាណិជ្ជកម្ម ភតិសន្យាហិរញ្ញវត្ថុ សេវាណែនាំពីផលិតផលធានារ៉ាប់រង និងសេវាកម្មធនាគារអេឡិចត្រូនិក។ ធនាគារ អេស៊ីលីដា ក៏ជាធនាគារកម្ពុជាដំបូងដែលបានពង្រីកប្រតិបត្តិការរបស់ខ្លួនទៅក្រៅប្រទេសដែលរួមមានប្រទេសឡាវ និងមីយ៉ាន់ម៉ា។ អេស៊ីលីដាបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។[31]

**រូបទី១៤៖ និមិត្តសញ្ញា ABC**

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៤.៣៩៤.៨៦៥ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ថ្ងៃទី០៣ ដល់ ថ្ងៃទី១៤/០៣/២០២០ |
| ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង | ១៥.០០០ រៀល ដល់ ១៧.៤០០ រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៤/០៣ ដល់ ថ្ងៃទី២៤/០៤/២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ១៦.២០០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

**តារាងទី៦៖ លទ្ធផលនៃ IPO របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី**

[31] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីធនាគារ អេស៊ីលីដា ភីអិលស៊ី
http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000100003 (ចូលថ្ងៃទី០១ ខែឧសភា ២០២២)

### ឆ. ផេសថិក

រូបទី១៥៖ និមិត្តសញ្ញា PEPC

ផេសថិក (ខេមបូឌា) បានចុះបញ្ជីក្នុងឆ្នាំ ២០១០ ជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនី ដែលផ្តល់សេវាសំខាន់លើការ ផ្តល់ជូនវិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយបច្ចេកទេសលើការគូសប្លង់ លទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ប្រើប្រាស់នូវអនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងបណ្តាញបញ្ជូនអគ្គិសនីដែលមាន តង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធថាមពលខ្សែកាបក្រោមដីសម្រាប់ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី និងការជួញដូរបង្គុំ និងបរិក្ខារប្រព័ន្ធថាមពលដែលជាកម្មសិទ្ធិ និងមិនមែនកម្មសិទ្ធិ។ ផេសថិកមានប្រភពចំណូលចំនួន ២ គឺការអនុវត្តគម្រោង និងការចែកចាយ ផលិតផល។ សម្រាប់ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនបានធ្វើការលើគម្រោងមួយចំនួននៅទូទាំងប្រទេសកម្ពុជា ដែលរួមមានការគូសប្លង់ វិស្វកម្ម ផ្គត់ផ្គង់ តម្លើង សាកល្បង និងដាក់ឱ្យប្រើប្រាស់នូវបណ្តាញបញ្ជូនអគ្គិសនី ប្រព័ន្ធបញ្ជូនអគ្គិសនី និងអនុស្ថានីយ៍។ គម្រោងទាំងនោះមានដូចជា គម្រោងរាជធានីភ្នំពេញខាងលិច-ខេត្តព្រះសីហនុ, គម្រោងខេត្តកំពង់ចាម-ក្រចេះ, គម្រោងបណ្តាញបញ្ជូនថាមពលស្ថានីយ៍វារីអគ្គិសនីស្ទឹងតាតៃ-ភ្នំពេញ, និងគម្រោងខេត្តសៀមរាប-ឧត្តរមានជ័យ។ ក្រុមហ៊ុន ផេសថិកបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០។[32]

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ផេសថិក (ខេមបូឌា) ម.ក |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៣.៩៤៥.០០០ |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៧/០៧/២០២០ ដល់ ថ្ងៃទី០៤/០៨/២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៣.១២០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អ អេច ប៊ី ស៊ីយូរីធី (ខេមបូឌា) ម.ក |

**តារាងទី៧៖ លទ្ធផលនៃ IPO របស់ផេសថិក (ខេមបូឌា)**

[32] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីផេសថិក (ខេមបូឌា) http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000140009 (ចូលថ្ងៃទី០១ ខែឧសភា ២០២២)

### ៩. ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ីនជីនារីង

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ីនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារផ្នែកវិស្វកម្ម និងសំណង់ដែលមានបទពិសោធជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌីប៊ីឌី ផ្តល់សេវាកម្មដូចជា សេវាកម្មគូរប្លង់ សាងសង់ តំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើឱ្យក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។ ឌីប៊ីឌី ទទួលបានកំណត់ត្រាជាទីគាប់ចិត្តក្នុងការផ្តល់សេវាកម្ម និងផ្គត់ផ្គង់ផលិតផលប្រកបដោយគុណភាព ដែលស្តែងបញ្ជាក់តាមរយៈការពេញចិត្ត និងការកោតសរសើរពីសំណាក់អតិថិជនរបស់ខ្លួន។ ក្រៅពីកេរ្តិ៍ឈ្មោះក្នុងផ្នែកសំណង់ ការបំពាក់ឧបករណ៍ និងសេវាកម្មថែទាំ ដែលបានឈានមុខគេក្នុងការផ្គត់ផ្គង់ផលិតផលម៉ាកល្បីៗជាច្រើនសម្រាប់គម្រោងនានាកន្លងមក ដែលរួមមានផលិតផលម៉ាក Scheneider ម៉ាក Franklin France ម៉ាក Daikin ម៉ាក Ginde ម៉ាក LG ម៉ាក Mitsubishi ម៉ាក Kumwell ម៉ាក EVT ម៉ាក Tsurumi Pump និងខ្សែកាបម៉ាក Yazaki។ ក្រុមហ៊ុន ឌី ប៊ី ឌីបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១។[33]

**រូបទី១៦៖ និមិត្តសញ្ញា DBDE**

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៦.៤៦១.៥៣៨ |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៦/០៧ ដល់ ថ្ងៃទី១៨/០៨/២០២១ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ២.៣៨០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី |

**តារាងទី៨៖ លទ្ធផលនៃ IPO របស់ឌី ប៊ី ឌី អ៊ិនជីនារីង**

[33] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីក្រុមហ៊ុន ឌី ប៊ី ឌី អ៊ីនជីនារីង http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000150008 (ចូលថ្ងៃទី០១ ខែឧសភា ២០២២)

**ឈ. ក្រុមហ៊ុនជេអេស លែន**

ក្រុមហ៊ុនជេអេស លែន ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៤ ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតក្រោមច្បាប់ស្តីពីសហ-គ្រាសពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនត្រូវបានបំលែងទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងអនុម័តយកនាមករណ៍បច្ចុប្បន្ននេះ កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ដើម្បីសម្រួលដល់ការធ្វើសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ អភិបាលរបស់ក្រុមហ៊ុនជេអេស លែន សុទ្ធតែជាសហគ្រិនដែលមានបទពិសោធន៍ច្រើន និងច្បាស់លាស់ នៅក្នុងវិស័យអភិវឌ្ឍន៍អចលនទ្រព្យ សណ្ឋាគារ ក៏ដូចជាវិស័យអភិវឌ្ឍន៍ដទៃទៀត ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់។ បេសកកម្មចម្បងរបស់ក្រុមហ៊ុន គឺសាងសង់លំនៅដ្ឋានដែលអាចបំពេញនូវរាល់តម្រូវការចាំបាច់របស់ប្រជាជនកម្ពុជា បូករួមជាមួយនឹងគុណភាពនៃលំនៅដ្ឋាន ដែលជម្រុញឱ្យការរស់នៅរបស់អតិថិជនពោរពេញទៅដោយភាពសម្បូរបែប។ ជេអេស លែនបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាផ្លូវការនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២។[34]

**រូបទី១៧៖ និមិត្តសញ្ញា JSL**

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ជេអេស លែន ភីអិលស៊ី |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៥.៧១០.០០០ |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី០៥ ដល់ ថ្ងៃទី១៤/០១/២០២២ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ១.៩០០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | ក្រុមហ៊ុន អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក |

**តារាងទី៩៖ លទ្ធផលនៃ IPO របស់ជេអេស លែន ភីអិលស៊ី**

## ៤.២.៥. វិនិយោគិន (Investors)

វិនិយោគិន គឺជាអ្នកដែលបែងចែកទុនរបស់ខ្លួន ដោយរំពឹងថានឹងទទួល បានចំណូលហិរញ្ញវត្ថុនាថ្ងៃអនាគត។ នៅក្នុងវិស័យមូលបត្រវិនិយោគិន សំដៅដល់សាធារណជនជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបាន លេខអត្តសញ្ញាណវិនិយោគិនពី ន.ម.ក. មានសិទ្ធិទិញឬលក់មូលបត្រ ដែលបានបោះផ្សាយ។

ប្រភពទុនរបស់វិនិយោគិនគឺបានមកពី សាច់ប្រាក់ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួន ការឧបត្ថម្ភ ឬកម្ចី ចំណូលពី

[34] ផ្សារមូលបត្រកម្ពុជា, សេចក្តីសង្ខេបអំពីក្រុមហ៊ុនជេអេស លែន ភីអិលស៊ី http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000160007 (ចូលថ្ងៃទី០១ ខែឧសភា ២០២២)

ការងារ ឬជំនួញ។ រីឯការប្រើប្រាស់សាច់ប្រាក់វិញគឺប្រើទៅលើ ការបើកសហគ្រាស (គំនិតជាសហគ្រិន) ដាក់ផ្ញើធនាគារ និងវិនិយោគលើមូលបត្រ។ ចំណាត់ថ្នាក់វិនិយោគិនបែងចែកជា រូបវន្តបុគ្គល និងនីតិបុគ្គល ហើយមានរយៈពេលវែង និងរយៈពេលខ្លី។

## ៤.៣. ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

### ៤.៣.១. គោលបំណង និងវិសាលភាពនៃអនុក្រឹតស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

គោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះ[35]៖

១. ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ ឬមូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២. មូលបត្ររដ្ឋ ដែលសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល ដូចដែលបានបញ្ញត្តនៅក្នុងមាត្រា៣ នៃច្បាប់ស្តីពីមូលបត្ររដ្ឋ។

៣. អ្នកវិនិយោគសាធារណៈដែលកាន់កាប់ និងទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ ឬ មូលបត្រ-បំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីទៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជន និងអនិវាសនជន។

### ៤.៣.២. ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី ន.ម.ក. និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ

[35] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ៤២ អនក្រ.បក, ២៤ កុម្ភៈ ២០២២, មាត្រា២

ន.ម.ក. នៅរាល់មុនការិយបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូល ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារដូចបានកំណត់។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ៣ ឆ្នាំ និងត្រូវគិតចាប់ផ្តើមពីៈ

១- ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២- ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ ខែ ចុងឆ្នាំជាប់ពន្ធ។

៣-អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។[36]

**ក. លក្ខខណ្ឌដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ត្រូវបានកំណត់អំពីលក្ខខណ្ឌដូចខាងក្រោមៈ

១- ក្រុមហ៊ុន/សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ ភាគរយ នៃសិទ្ធិបោះ-ឆ្នោត ឬបោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០ ភាគរយ នៃទ្រព្យសកម្មសរុប និងមានឥណប្រតិទានយ៉ាងតិច ៧ ឆ្នាំ នឹងទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់។

២- ក្រុមហ៊ុនដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំ ២០ ភាគរយ ឬតិចជាងនៃសិទ្ធិ បោះឆ្នោត ឬបោះផ្សាយមូលបត្របំណុលក្នុងទំហំ ២០ ភាគរយ ឬ តិចជាងនៃទ្រព្យសកម្មសរុបនឹងទទួលបាននូវការលើកទឹកចិត្តពន្ធតាមសមាមាត្រចុះដោយយក ២០,០០១ ជាគោល ដែលក្នុងនោះៈ

- ការបោះផ្សាយមូលបត្រកម្មសិទ្ធិៈ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រមិនឱ្យលើសពី ២០ ប៊ីលានរៀល។
- ការបោះផ្សាយមូលបត្របំណុល ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ៨ ប៊ីលានរៀល។
- ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលជាសាធារណៈ ដើម្បីទទួលបានហិរញ្ញប្បទានក្នុងគោលដៅនៃការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព ឬការអភិវឌ្ឍក្នុងវិស័យអាទិភាពណាមួយ នឹងទទួលបានការលើកទឹកចិត្តពន្ធដារពិសេស

[36] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ៤២ អនក្រ.បក, ២៤ កុម្ភៈ ២០២២, មាត្រា៣

បន្ថែមតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[37]

### ៤.៣.៣. ការលើកទឹកចិត្តពន្ធកាត់ទុក

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ ភាគរយ លើការប្រាក់ និង ភាគលាភដែលបានមកពីការកាន់កាប់ ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្រ បំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធនចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលសម្រាប់រយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និងភាគលាភត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកមុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែ បន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

ការកំណត់អត្រាពន្ធលើការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[38]

## ៤.៤. យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ដើម្បីសម្របសម្រួលដល់ការយល់ដឹង និងធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសារធារណៈលើកដំបូង ន.ម.ក. បានណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលបានចេញផ្សាយនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១១។[39]

### ៤.៤.១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក ន.ម.ក. ដែលលិខិតមានខ្លឹមសារ ០៣ ចំណុច ដូចខាងក្រោម៖

១- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២- គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣-ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

---

[37] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ៤២ អនក្រ.បក, ២៤ កុម្ភៈ ២០២២, មាត្រា៤

[38] អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ៤២ អនក្រ.បក, ២៤ កុម្ភៈ ២០២២, មាត្រា៦

[39] គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង, លេខ ០០១ គ.ម.ក/គ.ណ.ន

### ៤.៤.២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក.។

### ៤.៤.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី ន.ម.ក. ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬ ក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

### ៤.៤.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យ ជំនាញមេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

### ៤.៤.៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងទទួលការបញ្ជាក់ពី ន.ម.ក.

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**៤.៤.៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងការទទួល អនុញ្ញាតពី ន.ម.ក.**

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក ន.ម.ក.។ ន.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។

**៤.៤.៧. ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង**

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន. ម. ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**៤.៤.៨. ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពី ផ.ម.ក.**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**៤.៤.៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបានការ អនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក.**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯក-សារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជារួចដាក់ជូន ន.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**៤.៤.១០. ការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី

ន.ម.ក. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្ដើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

### ៤.៤.១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន ន.ម.ក.។

### ៤.៤.១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រ

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ៤.៥. លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅផ្សារមូលបត្រកម្ពុជា។

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោមមក ផ.ម.ក.[40]៖

១- ព័ត៌មានទូទៅ

- ក- ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងអក្សរឡាតាំង
- ខ- អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ
- គ- កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ
- ឃ- កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ
- ង- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- ច- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២-ព័ត៌មានអំពីបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ៖ អត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

[40] ប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី១០ កញ្ញា ២០១៥, ប្រការទី៧

៣- ព័ត៌មានអំពីភាគហ៊ុនិកៈ អត្តសញ្ញាណភាគហ៊ុនិក។

៤- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមានៈ

ក- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ

ខ- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ

គ- ការវាយតម្លៃទ្រព្យសកម្ម និង/ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

ឃ- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៥- ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមានៈ

ក- ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច

ខ- ព័ត៌មានអំពីហានិភ័យ។

៦- ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧- ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

## ៤.៦. លក្ខខណ្ឌនៃការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម[41]៖

- ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ ន.ម.ក.
- ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជារួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចសង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច
- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) ឬ របាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២ ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់ មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៤៥ ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ ហិរញ្ញវត្ថុក្នុងគ្រា

[41] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី១០ កញ្ញា ២០១៥, ប្រការទី៤

- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- ត្រូវមានឯកសារផ្តល់ព័ត៌មានដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

# ៤.៧. លក្ខណៈវិនិច្ឆ័យដែលគួរតែពិចារណាក្នុងការចុះបញ្ជី

## ៤.៧.១. លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម[42]៖

**ក.លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)**

ទីផ្សារគោលគឺជាផ្សារដំបូងបង្អស់ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការសម្រាប់ក្រុមហ៊ុនចុះបញ្ជីសក្តានុពលដែលមានស្តង់ដារ និងទំហំធំ។ ទីផ្សារចុះបញ្ជីនេះនឹងអនុញ្ញាតឱ្យក្រុមហ៊ុននាំយកភាគហ៊ុនទាំងអស់ក្រោយការបោះផ្សាយមកចុះបញ្ជី និងជួញដូរនៅក្នុងប្រព័ន្ធរបស់ ផ.ម.ក.។ លក្ខខណ្ឌរបស់ទីផ្សារគោលគឺ៖

- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ រៀលគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។
- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ រៀល នៃឆ្នាំ សារពើពន្ធ មុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ រៀល សម្រាប់រយៈពេល ២ ឆ្នាំចុងក្រោយ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ នាក់ គិតត្រឹមថ្ងៃបំពេញនីតិ-វិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ ន. ម. ក. តាមការស្នើសុំរបស់ ផ.ម.ក.។
- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយអគ្គនាយកនៃ ន.ម.កតាមការស្នើសុំរបស់ ផ.ម.ក.។

**ខ. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)**

ទីផ្សារថ្មីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យមត្រូវបានផ្តួចផ្តើមឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បី

[42] ប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី ១០ កញ្ញា ២០១៥, ប្រការ៨

បន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀតសម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះ ដែលមានផលសរុបប្រចាំឆ្នាំលើស ពី ១០ពាន់លានដុល្លារអាមេរិក និងបង្កើតការងារចំនួន ១.៣ លានផងដែរ។ ដោយមើលឃើញអំពីសក្តានុពលនៃ កំណើនរបស់សហគ្រាសទាំងនោះ គេឱ្យឈ្មោះទីផ្សារថ្មីនោះថា ទីផ្សារកំណើន។ លក្ខខណ្ឌសម្រាប់ទីផ្សារ កំណើនគឺ៖

- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២,០០០.០០០.០០០ រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះ បញ្ជីនៅ ផ. ម. ក.។
- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយ ដូចខាងក្រោម៖
  - ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
  - ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (Positive operating Cashflow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ ភាគរយ។
  - ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ ភាគរយ ដែលកាន់កាប់ភាគ ហ៊ុនចាប់ពី ១០ ភាគហ៊ុនឡើងទៅត្រូវមានចំនួនយ៉ាងតិច ១០០ នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធី ចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយក នៃ ន.ម.ក. តាមសំណើរបស់ ផ.ម.ក.។
  - ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិច ជាង ១ ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះ ឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ ន.ម.ក. តាម សំណើ របស់ ផ.ម.ក.។

### ៤.៧.២. លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវ បំពេញលក្ខខណ្ឌតម្រូវមិនមែនជាតួលេខដូចខាងក្រោម[43]៖

- មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ១ ឆ្នាំចុងក្រោយ រហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ។
- មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបាន ការអនុញ្ញាតពី គ. ម. ក.។

[43] ប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី ១០ កញ្ញា ២០១៥, ប្រការ៩

## ៤.៨. និតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បន្ទាប់ពីពិនិត្យឃើញពីគុណវុឌ្ឍិថា អាចបោះផ្សាយបាន ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវ[44]៖

- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ ន.ម.ក
- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ ន.ម.ក
- ដាក់ឯកសារភ្ជាប់ដូចបានកំណត់ក្នុងប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

### ៤.៨.១. ការដាក់ពាក្យស្នើសុំ

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូល-បត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបានបន្ទាប់ពី៖

- បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ
- បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី ន.ម.ក.។

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមទៅ ន.ម.ក.។ ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ ថ្ងៃគិតចាប់ពី កាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។

ការធ្វើបរិវិសកម្មត្រូវបានកំណត់ ២០% នៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ និង ៨០% ដែលនៅសល់ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។ ក្រុមហ៊ុនមូលបត្រត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្លៃដែលបានកំណត់នៅក្នុងឯក-សារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ ន.ម.ក.។ ក្រុមហ៊ុនបោះផ្សាយ ឬភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្ម ក្នុងរយៈពេល ១៥ ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើ

[44] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី១០ កញ្ញា ២០១៥, ប្រការទី៥

បរិវិសកម្ម។

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ ន.ម.ក. ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។ ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជា ផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត។ បន្ទាប់មកក្រុមហ៊ុនត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងច្បាប់ និងអនុក្រឹត្យ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ ន.ម.ក.។

### ៤.៨.២. ឯកសារផ្តល់ព័ត៌មាន

ឯកសារផ្តល់ព័ត៌មាន គឺជាលិខិតជូនដំណឹង ឬសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយអំពីប្រវត្តិក្រុមហ៊ុន របាយការណ៍ហិរញ្ញវត្ថុ ឬជាការអញ្ជើញឱ្យទិញ ឬសំណើឱ្យគេដាក់ពាក្យសុំទិញ ឬទិញមូលបត្រ ឬប្រកាសអំពីការដាក់លក់ ឬការលក់មូលបត្រ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចខាងក្រោម[45] ៖

១. ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ
២. ព័ត៌មានស្តីពីកត្តាហានិភ័យ
៣. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
៤. ផែនការវិនិយោគ
៥. ការពិពណ៌នាអំពីធុរកិច្ច
៦. ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ
៧. ការពិពណ៌នាអំពីអចលកម្មវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ
៨. ការវាយតម្លៃទ្រព្យសកម្ម ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ
៩. ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក
១០. ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់
១១. ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ
១២. ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
១៣. សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

[45] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី១០ កញ្ញា ២០១៥, ប្រការទី៧

១៤. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥. ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦. កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧. ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨. សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩. ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

**៤.៨.៣. ឯកសារភ្ជាប់**

ក្រៅពីឯកសារដែលបានរៀបរាប់ខាងលើនេះរួចមក ក្រុមហ៊ុនបោះផ្សាយក៏ត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំនូវឯកសារដូចខាងក្រោម[46]៖

១. លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ

២. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ

៣. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក

៤. លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់

៥. កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន

៦. កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈប្រសិនមាន

៧. ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច ១ ឆ្នាំ

៨. លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រស្តីពីការបើកគណនីដាច់ដោយឡែក សម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៩. កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ

១០. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ

១១. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ

[46] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី១០ កញ្ញា ២០១៥, ប្រការទី២៩

១២. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ
១៣. កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់
១៤. កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនមាន
១៥. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ពី ន.ម.ក. ករណីរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យដែលមិនមានការទទួលស្គាល់ពី ន.ម.ក.
១៦. របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់បំពេញចេញដោយមេធាវីដែលមាន គុណវុឌ្ឍិទទួលស្គាល់ដោយ ន.ម.ក.
១៧. ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

## ៤.៩. យន្តការនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម[47]

### ៤.៩.១. ដំណាក់កាលប៊ុកបៀលឌីង (Book-Building)

ការធ្វើប៊ុកបៀលឌីង ជាដំណាក់កាលស្ទាបស្ទង់ថ្លៃដែលធ្វើឡើងរវាងក្រុមហ៊ុនបោះផ្សាយមូលបត្រ និងវិនិយោគិនដែលស្ថិតក្រោមជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ គោលបំណងសំខាន់នៃការធ្វើប៊ុកបៀលឌីង គឺដើម្បីធានាបាននូវថ្លៃមួយដែលមានតម្លាភាព និងដើម្បីធានាថា ថ្លៃមូលបត្រកម្មសិទ្ធិបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ។ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីនិយ័តករមូលបត្រកម្ពុជា លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងបន្ទាប់ពីបានបំពេញតាមនីតិវិធីនានា ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រដែលធ្វើឡើងតាមរយៈការធ្វើប៊ុកបៀលឌីង ឬតាមការសម្រេចផ្សេងៗពីនេះ ដោយអគ្គនាយកនៃ ន.ម.ក តាមការស្នើសុំរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈដើម្បីអញ្ជើញវិនិយោគិនឱ្យចូលរួម។ មូលបត្រដែលត្រូវដាក់ឱ្យធ្វើ ប៊ុកបៀលឌីង មានចំនួន ៧០% នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលែបម្រុងទុកសម្រាប់បុគ្គលិក ក្នុងករណីក្រុមហ៊ុនមានគោលនយោបាយលើកទឹកចិត្តតាមរយៈការលក់ជូនបុគ្គលិក។ ដោយឡែក ៣០% ទៀតត្រូវលែបម្រុងទុកសម្រាប់ការធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

[47] គោលការណ៍ណែនាំស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ, លេខ០០២/១២ គ.ម.ក/គ.ណ.ន, ថ្ងៃទី០៩ កុម្ភៈ ២០១២

ចំពោះវិនិយោគិនដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួម ប៊ុក-បៀលឌីង (Book-Building Form) ដែលកំណត់ដោយ ន.ម.ក. ដោយត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិក្នុងឯកសារផ្តល់ព័ត៌មាន និងត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០% នៃថ្លៃមូលបត្រកម្មសិទ្ធិសរុប។ ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយត្រូវកំណត់ថ្លៃមូល-បត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពី ន.ម.ក. និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិនដែលទទួលបានជោគជ័យក្នុង ប៊ុកបៀលឌីង និងមិនជោគជ័យ។ វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិ-យោគិនដែលបានដាក់ថ្លៃ ខ្ពស់ជាង ឬស្មើថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price)។ ក្រុមហ៊ុនបោះផ្សាយ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted-Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។ ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនា អាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ ដោយមានការសម្រេចពី និយ័តករមូលបត្រកម្ពុជា។ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវធ្វើការជូនដំណឹងភ្លាមដល់វិនិយោគិនដែលទទួលបានជោគជ័យ និងមិនទទួលបានជោគជ័យបន្ទាប់ពី ន.ម.ក. បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវផ្ទេរប្រាក់កក់ ១០% ជូនវិនិយោគិនដែលមិនទទួល បានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីវិនិយោគិនមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីងមានបំណងបន្តធ្វើបរិវិសកម្ម។

### ៤.៩.២. ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ (Subscription)

ការធ្វើបរិវិសកម្មមូលបត្រ សំដៅដល់ដំណើរការនៃការស្នើសុំទិញមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។ សម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនដែលមានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។ តែចំពោះវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងវិញ ដែលមានបំណងបន្តធ្វើបរិវិសកម្ម អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។ វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០% នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបាន

លៃបំរុងសម្រាប់ធ្វើប៊ុកបៀលឌីង ហើយមានវិនិយោគិន ដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ប៉ុន្តែមិនទាន់ដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងអាចដកប្រាក់កក់ ១០% វិញបាន។

ករណីចំនួនមូលបត្រកម្មសិទ្ធិដែលបានស្នើសុំធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង និង/ឬសម្រាប់ការធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិតាមវិធានប្រូរ៉ាតា (Pro-Rata)។

ករណីចំនួនមូលបត្រកម្មសិទ្ធិដែលបានស្នើសុំធ្វើបរិវិសកម្មតិចជាងចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង និង/ឬសម្រាប់ការធ្វើបរិវិសកម្មដោយវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិន តាមការស្នើសុំធ្វើបរិវិសកម្ម។

ករណីមានចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្ម ក្រុមហ៊ុនធានាទិញមូលបត្រត្រូវទិញមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀងជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ។

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន ន.ម.ក. ភ្លាមដើម្បីស្នើសុំការពិនិត្យ និងសម្រេច។

បន្ទាប់ពីបានបញ្ចប់សព្វគ្រប់នូវដំណើរការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយមូលបត្រនឹងធ្វើការចុះបញ្ជី និងជួញដូរមូលបត្រកម្មសិទ្ធិរបស់ខ្លួននៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា តាមកាលកំណត់ដែលបានស្នើសុំ។

## ៤.១០. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវបង់ថ្លៃសេវា ផ.ម.ក. លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រចំនួន បួនលាន រៀលសម្រាប់ទីផ្សារគោល និងចំនួន ពីរលាន រៀលសម្រាប់ទីផ្សារកំណើន។[48]

### ៤.១០.១. ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវាដល់ ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រ ដោយផ្អែកលើមូលធនូបនីយកម្មទីផ្សារសុរប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជា

[48] ប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី ១០ កញ្ញា ២០១៥, ប្រការ២៣

សាធារណៈ ដែលត្រូវគណនាដេញជាដំណាក់តាមតារាងដូចខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ១០.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០៣០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០២៥% |
| ពី | ២០០.០០០.០០០.០០១៛ | ដល់ | ៤០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ៤០០.០០០.០០០.០០០៛ | ០,០១០% |

**តារាងទី១០៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ**

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវា ជ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូល-បត្រចំនួន ៤.០០០.០០០ រៀល (ថ្លៃអប្បបរមា) ឬ ចំនួន ០,០២៥ ភាគរយ នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈដោយយកចំនួនណាមួយដែលធំជាងគេ។

### ៤.១០.២. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ៣.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០២០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ៤០០.០០០.០០០.០០០៛ | ០,០០៥% |

**តារាងទី១១៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ**

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.០០០.០០០ រៀល (ថ្លៃសេវាប្រចាំឆ្នាំអប្បបរមា) ឬ ចំនួន ០,០១៥ ភាគរយ នៃ មូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយដោយយកចំនួនណាមួយដែលធំជាងគេ។

## ៤.១១. ពិភាក្សាទៅលើចំណុចខ្លាំង និងចំណុចខ្សោយនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ក្រោយពីបានធ្វើការស្រាវជ្រាវទៅលើដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិនៅកម្ពុជារួចមក នាងខ្ញុំអាចធ្វើការវិភាគទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់និយ័តករមូលបត្រ និងផ្សារមូលបត្រកម្ពុជា

បានដូចខាងក្រោម៖

### ៤.១១.១. ចំណុចខ្លាំង

- ការដាក់ឱ្យអនុវត្តនូវច្បាប់ បទបញ្ញត្តិ ប្រកាស និងគោលការណ៍ណែនាំ ដែលទាក់ទងនឹងវិស័យមូលបត្រ ដែលធ្វើឱ្យដំណើរការបោះផ្សាយមូលបត្រមានប្រសិទ្ធភាព
- ការដាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងមូលបត្រ អ្នកចូលរួមក្នុងទីផ្សារ និងទិន្នន័យទីផ្សារតាមរយៈគេហទំព័របានក្បោះក្បាយ ដែលជាហេតុងាយស្រួលដល់មហាជនក្នុងការទទួលយកព័ត៌មានបន្ថែម
- រដ្ឋាភិបាលក៏បានចូលរួមចំណែកក្នុងវិស័យមូលបត្រផងដែរ ដោយការលើកទឹកចិត្ត និងកាត់បន្ថយពន្ធដារ ដើម្បីជម្រុញឱ្យមានវិនិយោគិនចូលរួមកាន់តែច្រើន
- ការរៀបចំឡើងនូវសិក្ខាសិលាអប់រំ និងវគ្គបំប៉នខ្លីៗដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈទាក់ទងនឹងវិស័យមូលបត្រ
- មានកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលធ្វើឱ្យវិស័យមូលបត្រនៅកម្ពុជាកាន់តែប្រសើរឡើង
- មានកំណើននៃការ ចុះបញ្ជីរបស់ក្រុមហ៊ុនបោះផ្សាយនៅនិយ័តករមូលបត្រកម្ពុជា
- មានការបញ្ជាក់យ៉ាងច្បាស់អំពីសមាជិក និងអ្នកចូលរួមនៅក្នុងការជួញដូរមូលបត្រដែលទទួលបានការចុះបញ្ជីជាផ្លូវការពី ន.ម.ក. ក្នុងគោលបំណងជួយសម្រួលទៅដល់វិនិយោគិន និងក្រុមហ៊ុនដែលមានបំណងបោះផ្សាយមូលបត្រឱ្យមានភាពងាយស្រួលនៅក្នុងការសម្រេចចិត្តជ្រើសរើសអង្គភាពសម្របសម្រួល។

### ៤.១១.២. ចំណុចខ្សោយ

- មិនមានកម្មវិធីក្នុងទូរស័ព្ទដៃដើម្បីធ្វើការតាមដានពីការប្រកាសលទ្ធផលប៊ុកបៀលឌីង និងលទ្ធផលនៃការធ្វើបរិវិសកម្ម
- ចំណេះដឹងទាក់ទងនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅកម្ពុជា របស់វិនិយោគិនហាក់ដូចជានៅមានកម្រិតនៅឡើយ
- ក្រុមហ៊ុនចុះបញ្ជីក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានចំនួនតិច ដែលជាហេតុធ្វើឱ្យវិនិយោគិនមានជម្រើសតិចក្នុងការជ្រើសរើសក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសារ-ធារណៈ

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ដែលបានសិក្សាលើដំណើរការនៃកាបោះផ្សាយមូលបត្រកម្មសិទ្ធិជាសារធារណៈលើកដំបូងនៅកម្ពុជានេះរួចមក លទ្ធផលនេះបានផ្តល់នូវចំណេះដឹងជាច្រើន ក៏ដូចជាឆ្លើយតបទៅនឹងចំណោទបញ្ហារបស់នាងខ្ញុំដែលបានចោទឡើងមកដែរ។ ខ្ញុំបានសង្កេតឃើញថារាជរដ្ឋាភិបាលកម្ពុជាបានខិតខំយកចិត្តទុកដាក់លើក្នុងការអភិវឌ្ឍវិស័យមូលបត្រនេះឱ្យកាន់តែរីកចម្រើនតាមរយៈការបង្កើត និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។ រាជរដ្ឋាភិបាលក៏បានផ្តល់ការលើកទឹកចិត្ត ជាការកាត់បន្ថយពន្ធលើប្រាក់ចំណូល សម្រាប់សហគ្រាសដែលចុះបញ្ជីលក់មូលបត្រ, ទាំងមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល, និងកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់ លើភាគលាភ និងលើការប្រាក់ពាក់ព័ន្ធនឹងមូលបត្របំណុលតាំងពីទីផ្សារមូលបត្រកម្ពុជា បានចាប់ផ្តើមដំណើរការដំបូង ក្នុងឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន។ គិតត្រឹមខែមេសា ឆ្នាំ២០២២ នេះមានក្រុមហ៊ុនលក់មូលបត្រកម្មសិទ្ធិចំនួន៩រួចមកហើយ ដែលបានចុះបញ្ជីបោះផ្សាយមូលបត្រនៅ ន.ម.ក។ យោងទៅតាមរបាយការណ៍ស្ថិតិទីផ្សារមូលបត្រ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ បានបង្ហាញថា នៅត្រីមាសទី១ ឆ្នាំ២០២២នេះ សាច់ប្រាក់ដែលប្រមូលបានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសារធារណៈ ដែលត្រូវបានរួមបញ្ចូលទាំងទីផ្សារគោល និងទីផ្សារកំណើនមានចំនួន ១៥,៧៣៣,៩០០,000រៀល ដែលស្មើនឹង ៣,៨៦៧,២២៧ដុល្លារ។[49]

តាមការបកស្រាយពីខាងលើមក មុននឹងធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិបាន វិនិយោគិនត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួនដូចជា លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ លក្ខខណ្ឌការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និតីវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ការរៀបចំឯកសារផ្តល់ព័ត៌មាន និងយន្តការនានាដែលបានកំណត់ដោយ និយ័តករមូលបត្រផងដែរ។ ក្រៅពីនេះអត្ថបទស្រាវជ្រាវនេះ បានផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជាជាច្រើនដូចជា ប្រវត្តិ នាមករណ៍ និមិត្តសញ្ញា ទីតាំង រចនាសម្ព័ន្ធ និងព័ត៌មានសម្រាប់ទំនាក់ទំនងជាដើម។

សរុបសេចក្តីមក វិស័យមូលបត្រជាវិស័យថ្មីមួយនៅប្រទេសកម្ពុជា តែវិស័យនេះកាន់ឈានទៅមុខជាលំដាប់ ដោយនិយ័តករមូលបត្រកម្ពុជាបានទទួលការចុះបញ្ជីពីក្រុមហ៊ុនបោះផ្សាយមូលបត្រជាបន្តបន្ទាប់។ តែទោះបីជាមានក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិមានការកើនឡើងនៅកម្ពុជាក្តី តែចំនួននេះបើប្រៀបធៀបនឹងប្រទេសដទៃគឺនៅមានកម្រិតនៅឡើយទេ។ នេះជាមូលហេតុដែលធ្វើឱ្យវិនិយោគិនមានជម្រើសតិច ក្នុងការធ្វើការសម្រេចចិត្តវិនិយោគលើវិស័យមូលបត្រនេះ។

[49] និយ័តករមូលបត្រកម្ពុជា, របាយការណ៍ស្ថិតិទីផ្សារមូលបត្រ ត្រីមាសទី១ ឆ្នាំ២០២២, ទំព័រទី៤

## ២. អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវនិងបកស្រាយលើដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈនៅកម្ពុជានេះរួចមក យើងក៏បានបង្ហាញពីចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនរបស់ផ្សារមូលបត្រកម្ពុជា រួចមកឃើញថា រាល់ចំណុចល្អទាំងឡាយ ន.ម.គ និង ផ.ម.ក គួរតែរក្សាទុក រីឯចំណុចខ្វះខាតវិញ ស្ថាប័នពាក់ព័ន្ធគួរតែខិតខំកែលម្អនូវចំណុចទាំងនោះដើម្បីពង្រឹងបន្ថែមលើការអភិវឌ្ឍរបស់ខ្លួន។ ដើម្បីចូលរួមចំណែកក្នុងការរីកចម្រើនក្នុងវិស័យមូលបត្រ នាងខ្ញុំសូមធ្វើការផ្តល់នូវមតិយោបល់មួយចំនួនដូចជាៈ

- បង្កើតជាកម្មវិធីទូរស័ព្ទដៃ ដើម្បីងាយស្រួលដល់វិនិយោគិនដឹងពីលទ្ធផលប៊ុកបៀលឌីង និងលទ្ធផលនៃការធ្វើបរិវិសកម្ម
- គួរតែមានការផ្សព្វផ្សាយពីវិស័យមូលបត្រនេះឱ្យបានច្រើនតាមវេទិកា សិក្ខាសាលា ឬតាមបណ្តាញផ្សព្វផ្សាយ ជាពិសេសតាមបណ្តាក្រុមហ៊ុនធំៗនានានៅកម្ពុជា ដើម្បីទាក់ទាញអ្នកវិនិយោគទាំងនោះឱ្យមកចុះបញ្ជីក្នុងនិយ័តករមូលបត្រកាន់តែច្រើន
- គួរតែជម្រុញដល់គ្រឹះស្ថានសាធារណៈនិងឯកជនឱ្យធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈឱ្យកាន់តែច្រើន ដើម្បីឱ្យក្រុមហ៊ុនទាំងនោះអាចប្រមូលដើមទុនយកទៅប្រើប្រាស់

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខ នស/រកម/១០០៧/០២៨, ០៧ កញ្ញា ២០០៧
- ច្បាប់ស្តីពីមូលបត្ររដ្ឋ, លេខ នស/រកម/០១០៧/០០១, ១០ មករា ២០០៧
- អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ, លេខ៤២ អនក្រ.បក, ២៤ កុម្ភៈ ២០២២
- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ, លេខ០០៦/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី ១០ កញ្ញា ២០១៥
- ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ, លេខ០០៥/១៥ គ.ម.ក/ប្រ.ក, ថ្ងៃទី ១០ កញ្ញា ២០១៥

## គោលការណ៍ណែនាំ

- គោលការណ៍ណែនាំស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ, លេខ០០២/១២ គ .ម.ក/គ.ណ.ន, ថ្ងៃទី០៩ កុម្ភៈ ២០១២
- គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង, លេខ ០០១ គ.ម.ក/គ.ណ.ន

## សៀវភៅ អត្ថបទ និងឯកសារស្រាវជ្រាវ

- រាជរដ្ឋាភិបាលកម្ពុជា.២០១៦. *យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥*
- និយ័តករមូលបត្រកម្ពុជា.២០១៧. *មគ្គុទេសក៍ស្តីពី ការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា*
- និយ័តករមូលបត្រកម្ពុជា.២០២២. *របាយការណ៍ស្ថិតិទីផ្សារមូលបត្រ ត្រីមាសទី១ ឆ្នាំ២០២០*
- សាស្ត្រាចារ្យ បៀន សាំង.២០១១. *មូលដ្ឋានគ្រឹះទីផ្សារមូលបត្រ*. សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សាស្ត្រាចារ្យ ហេងច័ន្ទបូលីន.*ទីផ្សារមូលបត្រកម្ពុជា*. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សុធី មេត្តា. ២០២០. *ដំណើរការទីផ្សារមូលបត្រនៅកម្ពុជា*. និក្ខេបបទបរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ឯកសារនិងទិន្នន័យដកស្រង់ពីគេហទំព័រ


- The World Bank, *GDP growth (annual %)* – Cambodia. https://data.worldbank.org/indicator/NY.GDP.MKTP.KD.ZG?end=2020&locations=KH&name_desc=false&start=1994 (ចូលថ្ងៃទី២៦ មីនា ២០២២)
- និយ័តករមូលបត្រកម្ពុជា (២០១៦), *ពុទ្ធិមូលបត្រ៖ តួអង្គសំខាន់ៗទាំង ៤ ក្នុងទីផ្សារមូលបត្រ (4Is)* (លេខ VII ចេញផ្សាយឆ្នាំ២០១៦), https://www.serc.gov.kh/khmer/m46.php?pn=2
- និយ័តករមូលបត្រកម្ពុជា (២០១៦), *ពុទ្ធិមូលបត្រ៖ ប្រវត្តទីផ្សារភាគហ៊ុន* (ចេញផ្សាយប្រចាំសប្តាហ៍ទី៤ ខែសីហា ឆ្នាំ២០១៦) https://www.serc.gov.kh/khmer/m46.php?pn=2
- និយ័តករមូលបត្រកម្ពុជា (២០១៦), *ពុទ្ធិមូលបត្រ៖ ភាគហ៊ុនធម្មតា និង ភាគហ៊ុនបុរិមា* (ចេញផ្សាយប្រចាំសប្តាហ៍ទី៣ ខែកញ្ញា ឆ្នាំ២០១៦) https://www.serc.gov.kh/khmer/m46.php?pn=2
- និយ័តករមូលបត្រកម្ពុជា (២០១៦), *ពុទ្ធិមូលបត្រ៖ អត្ថប្រយោជន៍ទីផ្សារភាគហ៊ុនចំពោះវិនិយោគិន* (លេខ VI ចេញផ្សាយឆ្នាំ២០១៦) https://www.serc.gov.kh/khmer/m46.php?pn=2
- និយ័តករមូលបត្រកម្ពុជា (២០១៩), *ពុទ្ធិមូលបត្រ៖ ប្រភេទមូលបត្រនៅកម្ពុជា* (លេខ៣៥ ចេញផ្សាយឆ្នាំ២០១៩) https://www.serc.gov.kh/khmer/m46.php?pn=2
- និយ័តករមូលបត្រកម្ពុជា (២០២០), *រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជា* https://www.serc.gov.kh/khmer/m17.php?pn=1 (ចូលថ្ងៃទី១៦ មេសា ២០២២)
- ប៉ុស្តិ៍មូលបត្រ៖ ចំណេះដឹងមូលដ្ឋាន, *តួនាទីរបស់ទីផ្សារមូលបត្រក្នុងការជំរុញកំណើនសេដ្ឋកិច្ច*, (ចេញផ្សាយថ្ងៃទី១ មិថុនា ២០២០) http://www.csx.com.kh/common/publications/fileDownload.do (ចូលថ្ងៃទី១៦ មេសា ២០២២)
- ផ្សារមូលបត្រកម្ពុជា, *ចក្ខុវិស័យ & បេសកកម្ម* http://csx.com.kh/kh/about/mission.jsp?MNCD=1020 (ចូលថ្ងៃទី១៨ មេសា ២០២២)
- ផ្សារមូលបត្រកម្ពុជា, *បញ្ជីឈ្មោះក្រុមហ៊ុន* http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលថ្ងៃទី២៥ មេសា ២០២២)
- ផ្សារមូលបត្រកម្ពុជា, ប្រវត្តិ ផមក, http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលថ្ងៃទី១៨ មេសា ២០២២)
- ផ្សារមូលបត្រកម្ពុជា, អត្ថប្រយោជន៍ http://csx.com.kh/kh/product/blisting.jsp?MNCD=30101 (ចូលថ្ងៃទី១៥ មេសា ២០២២)

- ផ្សារហ៊ុន.២០១៨. អត្ថប្រយោជន៍នៃទីផ្សារភាគហ៊ុន, https://phsarhun.com/news/45 ( ចូលថ្ងៃទី ១៥ មេសា ២០២២
- ភ្នំពេញប៉ុស្ដិ៍, ប្រធានបទទី១៖ តួនាទីគណៈកម្មការមូលបត្រកម្ពុជា, ២០២០, https://www.postkhmer.com/សេដ្ឋកិច្ច/ប្រធានបទទី-១៖-តួនាទីគណៈកម្មការមូលបត្រកម្ពុជា ( ចូលថ្ងៃទី១៦ មេសា ២០២២ )

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ឧបសម្ព័ន្ធទី២ ៖ ពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង

ឧបសម្ព័ន្ធទី៣ ៖ ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិសម្រាប់វិនិយោគិនដែលបានចូលរួមធ្វើប៊ុកបៀលឌីង

ឧបសម្ព័ន្ធទី៤ ៖ ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិសម្រាប់វិនិយោគិនដែលមិនបានចូលរួមធ្វើប៊ុក-បៀលឌីង

# ឧបសម្ព័ន្ធទី១៖

# ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:...........................គ.ម.ក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ[១]

**ផ្នែកទី ១: ព័ត៌មានទូទៅ**

**១- ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ**

ឈ្មោះជាអក្សរខ្មែរ: ______________________

ឈ្មោះជាអក្សរឡាតាំង: ______________________

ឈ្មោះជាអក្សរកូដ: ______________________

ប្រភេទធុរកិច្ចជាភាសាខ្មែរ: ______________________

ប្រភេទធុរកិច្ចជាភាសាអង់គ្លេស: ______________________

អាសយដ្ឋានទីស្នាក់ការចុះបញ្ជី: ______________________

លេខទូរស័ព្ទ: ____________ លេខទូរសារ: ____________

គេហទំព័រ: ____________ អ៊ីម៉ែល: ____________

កាលបរិច្ឆេទចាប់ផ្តើមដំណើរការអាជីវកម្ម: ________/________/________

លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: ______________________

---

១ពាក្យស្នើសុំនេះ ត្រូវដាក់ជូន **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវឯកសារផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងទៀត។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្មៈ ____________/____________/ ____________

លេខអាជ្ញាបណ្ណអាជីវកម្មៈ ____________ចេញដោយ: ____________

សុពលភាពអាជ្ញាបណ្ណអាជីវកម្ម ពីថ្ងៃទី: ______/______/______ ដល់ថ្ងៃទី: ______/______/______

លេខអត្តសញ្ញាណកម្មសារពើពន្ធៈ ____________

**២- ព័ត៌មានអំពីបុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន**

ឈ្មោះជាអក្សរខ្មែរៈ ____________

ឈ្មោះជាអក្សរឡាតាំងៈ ____________

លេខអត្តសញ្ញាណប័ណ្ណ /លេខលិខិតឆ្លងដែនៈ ____________

មុខតំណែងៈ ____________

អាសយដ្ឋានៈ ____________

លេខទូរស័ព្ទៈ ____________ លេខទូរសារៈ ____________

លេខទូរស័ព្ទដៃៈ ____________ អ៊ីម៉ែលៈ ____________

## ផ្នែកទី ២: ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិ

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ | |
| ប្រភេទមូលបត្រកម្មសិទ្ធិ | |
| ថ្នាក់មូលបត្រកម្មសិទ្ធិ | |
| ថ្លៃលក់ | |
| ចំនួនមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ | |
| ចំនួនទឹកប្រាក់សរុបពីការបោះផ្សាយ | |

## ផ្នែកទី ៣: មូលធនភាគហ៊ុនិក និងចំណេញភាព

| ឃរិយាយ | ទឹកប្រាក់ជារៀល | ទឹកប្រាក់ជាដុល្លារ |
|---|---|---|
| មូលធនភាគហ៊ុនិកសរុបនៅកាលបរិច្ឆេទដាក់ពាក្យស្នើសុំ | | |

| | | |
|---|---|---|
| ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ | | |
| ចំណេញសុទ្ធក្នុងរយៈពេលបីឆ្នាំចុងក្រោយ | | |

*សូមផ្តល់នូវអត្រាប្តូរប្រាក់ដូចគ្នានឹងអត្រាដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។*

## ផ្នែកទី ៤: រចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន និងភាគហ៊ុនិក

១- សូមភ្ជាប់មកជាមួយនូវរចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយបញ្ជាក់ដូចខាងក្រោម: រចនាសម្ព័ន្ធជាក្រុម

- ភាគរយនៃភាគហ៊ុនរបស់ក្រុមនីមួយៗ
- សកម្មភាពធុរកិច្ចគោលរបស់ក្រុមនីមួយៗ

២- បញ្ជីភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ:

| ល.រ. | ឈ្មោះភាគហ៊ុនិក | ចំនួនភាគហ៊ុន | ភាគរយ | ថ្នាក់មូលបត្រ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

*សូមភ្ជាប់នូវបញ្ជីតាមទម្រង់នេះ ករណីភាគហ៊ុនិកកាន់ភាគហ៊ុនចាប់ពី ០៥ (ប្រាំ) ភាគរយ មានចំនួនលើសពីនេះ។*

## ផ្នែកទី ៥: ព័ត៌មានអំពីអភិបាល

បំពេញព័ត៌មានពាក់ព័ន្ធនឹងអភិបាលដូចខាងក្រោម:

| ល.រ. | ឈ្មោះអភិបាល | ប្រភេទអភិបាល | លេខអត្តសញ្ញាណប័ណ្ណ / លេខលិខិតឆ្លងដែន | សេចក្តីលម្អិតពីលិខិតឆ្លងដែន | | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|---|---|
| | | | | កាលបរិច្ឆេទអស់សុពលភាព | ចេញដោយប្រទេស | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |

*សូមភ្ជាប់នូវព័ត៌មានតាមទម្រង់នេះ ករណីអភិបាលមានចំនួនលើសពីនេះ។*

## ផ្នែកទី ៦: ព័ត៌មានអំពីបុគ្គលិកជាន់ខ្ពស់

បំពេញព័ត៌មានពាក់ព័ន្ធនឹងបុគ្គលិកជាន់ខ្ពស់ដូចខាងក្រោម:

| ល.រ. | ឈ្មោះបុគ្គលិកជាន់ខ្ពស់ | មុខតំណែង | លេខអត្តសញ្ញាណប័ណ្ណ /លេខលិខិតឆ្លងដែន | សេចក្តីលម្អិតពីលិខិតឆ្លងដែន | | កាលបរិច្ឆេទតែងតាំង |
|---|---|---|---|---|---|---|
| | | | | កាលបរិច្ឆេទអស់សុពលភាព | ចេញដោយប្រទេស | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

*សូមភ្ជាប់នូវព័ត៌មានតាមទម្រង់នេះ ករណីបុគ្គលិកជាន់ខ្ពស់មានចំនួនលើសពីនេះ។*

## ផ្នែកទី ៧: ព័ត៌មានអំពីក្រុមហ៊ុនហុលឌីង ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ

១- តើក្រុមហ៊ុនបោះផ្សាយ មានក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដែរឬទេ?

□ មាន □ គ្មាន

ប្រសិនមាន សូមផ្តល់នូវព័ត៌មានដូចខាងក្រោម:

| ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | លេខអាជ្ញាបណ្ណ ឬ លេខចុះបញ្ជី | កាលបរិច្ឆេទក្លាយជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

*សូមភ្ជាប់នូវព័ត៌មានដូចទម្រង់ខាងលើ ករណីក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ មានចំនួនលើសពីនេះ។*

២- តើក្រុមហ៊ុនបោះផ្សាយ ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធដទៃដែរឬទេ?

□ មែន □ មិនមែន

ប្រសិនបើមែន សូមផ្តល់នូវព័ត៌មានដូចខាងក្រោម:

| ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយ % | កាលបរិច្ឆេទក្លាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬបុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ផ្នែកទី ៨: ព័ត៌មានអំពីការបោះផ្សាយមូលបត្រជាសាធារណៈពីមុន

តើក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែរឬទេ?

□ ធ្លាប់ សូមបំពេញនូវតារាងខាងក្រោម

□ មិនធ្លាប់

ឈ្មោះមូលបត្រកម្មសិទ្ធិ ______________________

ថ្ងៃលក់: ______________________

ចំនួនមូលបត្រកម្មសិទ្ធិ: ______________________

ទឹកប្រាក់សរុប: ______________________

កាលបរិច្ឆេទចុះបញ្ជីពីមុន: ______________________

ទីកន្លែងជួញដូរ: ______________________

## ផ្នែកទី ៩: ព័ត៌មានអំពីការបដិសេធឯកសារផ្ដល់ព័ត៌មាន

តើក្រុមហ៊ុនធ្លាប់ត្រូវបានបដិសេធឯកសារផ្ដល់ព័ត៌មានដែរឬទេ?

□ ធ្លាប់ សូមបំពេញនូវតារាងខាងក្រោម

□ មិនធ្លាប់

| ឈ្មោះអាជ្ញាធរ | ប្រភេទនៃការបដិសេធ | ហេតុផលនៃការបដិសេធ | លេខយោង |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

## ផ្នែកទី ១០: ព័ត៌មានអំពីភាគីពាក់ព័ន្ធ

១- **ក្រុមហ៊ុនគណនេយ្យជំនាញ**: ______________________

កាលបរិច្ឆេទតែងតាំង ________/________/________

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:____/____/____ ដល់ថ្ងៃទី:____/____/____

២- **ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ**: ______________________

កាលបរិច្ឆេទតែងតាំង ________/________/________

សុពលភាពនៃអាជ្ញាបណ្ណ ពីថ្ងៃទី:______/______/______ ដល់ថ្ងៃទី:______/______

៣- **មេធាវី** ______________________________

កាលបរិច្ឆេទតែងតាំង ______________/______________/______________

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:____/____/____ ដល់ថ្ងៃទី:____/____/____

៤- **ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ** ______________________________

កាលបរិច្ឆេទតែងតាំង ______________/______________/______________

សុពលភាពនៃការទទួលស្គាល់ដោយ **គ.ម.ក.**ពីថ្ងៃទី:____/____/____ ដល់ថ្ងៃទី:____/____/____

## ផ្នែកទី ១១: ឯកសារភ្ជាប់

បុគ្គលដែលស្នើសុំធ្វើសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនូវឯកសារដូចខាងក្រោម:

១- ឯកសារផ្តល់ព័ត៌មាន ដែលរៀបចំឡើងដោយអនុលោមតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

២- វិញ្ញាបនបត្របញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិពីទីផ្សារមូលបត្រប្រតិស្រុត។

៣- លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៤- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ។

៥- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៦- លិខិតប្រគល់សិទ្ធិដោយមានបញ្ជាក់ពីតួនាទី និងភារកិច្ចជាអភិបាល ឬនាយកប្រតិបត្តិ ក្នុងការបម្រើការងារនៅក្នុងក្រុមហ៊ុនបោះផ្សាយ ដោយមានការចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៧- កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗ (ប្រសិនបើមាន)។

៨- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩- កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្ម ជានាទិញមូលបត្រ។

១១- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣- កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤- កិច្ចព្រមព្រៀងវិនិយោគចម្រុះសំខាន់ៗ ប្រសិនបើមាន។

១៥- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជ ឬលិខិតបញ្ជាក់ពីសវនករនូវចំនួនទឹកប្រាក់តម្កល់សម្រាប់ធ្វើជាមូលធន។

១៦- របាយការណ៍អនុសាសន៍ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់សវនករឯករាជ្យដែលមានគុណវុឌ្ឍិទទួលស្គាល់ ដោយ **គ.ម.ក.**។

១៧- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យចេញដោយ ក្រុមហ៊ុនគណនេយ្យជំនាញដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.**។

១៨- របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ ដោយ **គ.ម.ក.**។

១៩- បញ្ជីរាយនាមអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនដែលមានលក្ខណៈបច្ចុប្បន្នភាពដោយភ្ជាប់ មកជាមួយប្រវត្តិរូបសង្ខេបរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ និងបទពិសោធន៍ការងារ។

២០- លិខិតផ្ទេរសិទ្ធិជូនបុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

២១- អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែនថតចម្លង របស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន។

២២- ប្រវត្តិរូបសង្ខេបរបស់បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ដោយបញ្ជាក់ពីរយៈពេល បំពេញការងារ និងបទពិសោធន៍ការងារ។

២៣- បញ្ជីរាយនាម និងអត្តសញ្ញាណរបស់ភាគហ៊ុនិកដែលមានលក្ខណៈបច្ចុប្បន្នភាព។

២៤- ឯកសារភ្ជាប់ផ្សេងៗទៀត តាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ផ្នែកទី ១២: សេចក្តីប្រកាស និងកិច្ចសន្យារបស់បុគ្គលដាក់ពាក្យស្នើសុំ**

- ក្រុមហ៊ុនសូមអះអាងថា រាល់ព័ត៌មានដែលបានផ្តល់នៅក្នុងពាក្យស្នើសុំ (រួមមានរាល់ព័ត៌មានពាក់ព័ន្ធ និង ឯកសារភ្ជាប់) មានលក្ខណៈពេញលេញ ពិតប្រាកដ និងត្រឹមត្រូវ។
- ក្រុមហ៊ុនសូមអះអាងថា ក្រុមប្រឹក្សាភិបាលបានផ្តល់សេចក្តីសម្រេចយល់ព្រមលើពាក្យស្នើសុំនេះ។

- ក្រុមហ៊ុនដឹងថា ការផ្តល់ព័ត៌មានខុស ឬព័ត៌មានដែលនាំឱ្យយល់ខុសដែលភ្ជាប់មកជាមួយនឹងពាក្យស្នើសុំសម្រាប់ចុះបញ្ជីគឺជាបទល្មើសដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។
- ក្រុមហ៊ុនដឹងថា **គ.ម.ក.** មានសមត្ថកិច្ចគ្រប់ពេលវេលាក្នុងការចាត់វិធានការណ៍ចំពោះការក្លែងបន្លំព័ត៌មាន នៅក្នុងឯកសារផ្តល់ព័ត៌មាន ឯកសារភ្ជាប់ និងពាក្យស្នើសុំ។
- ក្រុមហ៊ុនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមមក **គ.ម.ក.** ប្រសិនបើមានការផ្លាស់ប្តូរពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាន ឯកសារភ្ជាប់ និងពាក្យស្នើសុំ មុនពេលពាក្យស្នើសុំទទួលបានការយល់ព្រម។

## ផ្នែកទី ១៣: ការបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត

ពាក្យស្នើសុំការទទួលស្គាល់ត្រូវភ្ជាប់មកជាមួយនូវវិក័យបត្រ ជាសាច់ប្រាក់ចំនួន ១២.០០០.០០០(ដប់ពីរលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬជាសាច់ប្រាក់ចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម សម្រាប់ពាក្យស្នើសុំ និងសោហ៊ុយសិក្សានិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ដោយយោងតាមប្រការ ៤៧ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

រាជធានីភ្នំពេញ ថ្ងៃទី :____/______/______

ហត្ថលេខា និងត្រា

ឈ្មោះ:..................

(បុគ្គលមានសិទ្ធិអំណាចចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន)

# ឧបសម្ព័ន្ធទី២៖
# ពាក្យស្នើសុំចូលរួមធ្វើ
# ប៊ិកបៀលឌីង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:...............................គ.ម.ក

ឧបសម្ព័ន្ធ ០១

(លេខប៊ុកបៀលឌីង :...............................)

## ពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង
## នៃក្រុមហ៊ុន ...............................................

### ព័ត៌មានពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនធានាទិញមូលបត្រ និងមូលបត្រកម្មសិទ្ធិ

យើងខ្ញុំជាក្រុមហ៊ុនធានាទិញមូលបត្រ :.......................................................................................
.....................................................................................................។

ក្រុមហ៊ុនបោះផ្សាយ :........................................................ បានតែងតាំងក្រុមហ៊ុនមូលបត្រយើងខ្ញុំ.......................................................................... (ឈ្មោះក្រុមហ៊ុនមូលបត្រ) ធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រ កាលពីថ្ងៃទី ........ ខែ ........ ឆ្នាំ ........... ។

SPECIMEN

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រយើងខ្ញុំ បានដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មានជូន គ.ម.ក. ហើយទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. នៅថ្ងៃទី ...... ខែ ......... ឆ្នាំ .........។ ក្រុមហ៊ុនបោះផ្សាយបានកំណត់ថ្លៃលក់ចន្លោះពី..................... ដល់.................................. ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។

យើងខ្ញុំសូមបញ្ជាក់ថា វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ (Book-Building) ត្រូវជ្រើសរើសថ្លៃណាមួយក្នុងចំណោមចន្លោះថ្លៃដែលក្រុមហ៊ុនបានកំណត់។ វិនិយោគិនដែលចូលរួមក្នុងការស្ទាបស្ទង់ថ្លៃលក់មូលបត្រ ត្រូវតម្កល់ប្រាក់ស្មើនឹង ១០ (ដប់) ភាគរយ នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលមានបំណងធ្វើបរិវិសកម្ម (សូមអានគោលការណ៍ណែនាំរបស់ គ.ម.ក. ស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដែលអាចទាញយកតាម http://www.secc.gov.kh/khmer/m24.php?pn=3 )។

វិនិយោគិនដែលមានបំណងចូលរួមក្នុងការស្ទាបស្ទង់ថ្លៃ សូមបំពេញនូវព័ត៌មាន ដូចខាងក្រោម÷

### ព័ត៌មានពាក់ព័ន្ធនឹងវិនិយោគិនចូលរួមធ្វើប៊ុកបៀលឌីង

**ក. វិនិយោគិនជារូបវន្តបុគ្គល:**

□រូបវន្តបុគ្គលសញ្ជាតិខ្មែរ □រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :.................................................. ជាអក្សរឡាតាំង :..................................................

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

ថ្ងៃខែឆ្នាំកំណើត :...................................................... ភេទ : □ ប្រុស □ ស្រី

ទូរស័ព្ទលេខ :...................................................... អ៊ីម៉ែល :......................................................។

លេខអត្តសញ្ញាណវិនិយោគិន[១] :........................................

**ខ. វិនិយោគិនជានីតិបុគ្គល :**

□នីតិបុគ្គលសញ្ជាតិខ្មែរ □នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :.............................................. ជាអក្សរឡាតាំង :..............................................

លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) ..................................

ទូរស័ព្ទលេខ :...................................................... អ៊ីម៉ែល :......................................................។

លេខអត្តសញ្ញាណវិនិយោគិន[២] :........................................

SPECIMEN

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើប៊ុកបៀលឌីងតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

## ព័ត៌មានពាក់ព័ន្ធនឹងការស្ទាបស្ទង់ថ្លៃលក់មូលបត្រកម្មសិទ្ធិ

១. ថ្លៃមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :..............................................។

(វិនិយោគិន ត្រូវជ្រើសរើសយកថ្លៃមួយក្នុងចន្លោះថ្លៃ ដូចបានកំណត់ខាងលើ)

២. ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម :..............................................

៣. ចំនួនទឹកប្រាក់សរុប (ថ្លៃមូលបត្រកម្មសិទ្ធិ x ចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនមានបំណងធ្វើបរិវិសកម្ម) :..............................................................។

ធ្វើនៅ................ ថ្ងៃទី......... ខែ........ ឆ្នាំ...........

ហត្ថលេខា ឬ/និង ត្រា[៣]

ហត្ថលេខា-ត្រា និងឈ្មោះ

....................................

**តំណាងក្រុមហ៊ុនមូលបត្រ**

ឈ្មោះវិនិយោគិន

[១] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[២] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៣] ករណីវិនិយោគិនជានីតិបុគ្គល

## គំរូវិក្កយបត្រ
## ប៉ុកបៀលនឹងមូលបត្រ

**វិក្កយបត្រប្រាក់តម្កល់នៃក្រុមហ៊ុនមូលបត្រ....................**

លេខប៉ុកបៀលនឹង:........................

SPECIMEN

កាលបរិច្ឆេទ : __/__/____

អ្នកធ្វើប៉ុកបៀលនឹងឈ្មោះ :..........................................

លេខអត្តសញ្ញាណវិនិយោគិន :..........................................

ចំនួនទឹកប្រាក់សរុបបានទទួល :..........................................

មធ្យោបាយទូទាត់ : □ ប្រាក់សុទ្ធ

□ បណ្ណឥណទាន

□ មូលប្បទានបត្រលេខ : ........................ ធនាគារ :..............................។

ហត្ថលេខា- ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

# ឧបសម្ព័ន្ធទី៣៖

# ពាក្យស្នើសុំធ្វើបរិវិសកម្ម
# មូលបត្រកម្មសិទ្ធិសម្រាប់
# វិនិយោគិនដែលបានចូល
# រួមធ្វើប៉ុកប៉ៀលឌីង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:.............................គ.ម.ក

ឧបសម្ព័ន្ធទី ០២

**លេខបរិវិសកម្ម :.............................**

## ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ
## សម្រាប់វិនិយោគិនដែលបានចូលរួមធ្វើប៊ុកបៀលឌីង
## ក្រុមហ៊ុនបោះផ្សាយ.............................................................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន ............................ ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ........................ ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង .......................។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់បុគ្គលិកមានចំនួន .................. ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ................................ ឯកតាមូលបត្រកម្មសិទ្ធិ។

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី .................................ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនដងនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

SPECIMEN

**ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម**

ឈ្មោះជាអក្សរខ្មែរ :........................................... ជាអក្សរឡាតាំង :...............................................

លេខប៊ុកបៀលឌីង :........................................... លេខអត្តសញ្ញាណវិនិយោគិន :.................................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................. លេខគណនីជួញដូរ[១] :........................

[១] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

ក. វិនិយោគិនដែលទទួលបានជោគជ័យ

| ចំនួនមូលបត្រកម្មសិទ្ធិដែលបានបម្រុងឱ្យក្នុងប៊ុកបៀលឌីង | ចំនួនទឹកប្រាក់តម្កល់ជាក់ស្ដែងសរុបសម្រាប់ប៊ុកបៀលឌីង (១) |
|---|---|
| ......................................... | ......................................... |
| ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
| ......................................... | ......................................... |
| ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) - (១) | |
| ................................................................................ | |

SPECIMEN

ខ. វិនិយោគិនដែលមិនទទួលបានជោគជ័យ

| ចំនួនទឹកប្រាក់តម្កល់ជាក់ស្ដែងសរុបសម្រាប់ប៊ុកបៀលឌីង (១) | ចំនួនមូលបត្រកម្មសិទ្ធិដែលស្នើសុំធ្វើបរិវិសកម្ម | ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់សម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) |
|---|---|---|
| ......................................... | ......................................... | ......................................... |
| ចំនួនទឹកប្រាក់បង់បន្ថែមសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម (២) - (១) | | |
| ................................................................................ | | |

## សេចក្ដីថ្លែងសម្រាប់វិនិយោគិនដែលចូលរួមក្នុងបរិវិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្ដល់ព័ត៌មានក្នុងទម្រង់ជា÷

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ :........................................ ឬ ☐ ផ្សេងពីនេះ : ........................................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្ដល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញ

មូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម : __/__/____

SPECIMEN

| ហត្ថលេខា ត្រា និងឈ្មោះ | ហត្ថលេខា ឬ/និងត្រា[២] |
|---|---|
| ........................................ | ........................................ |
| តំណាងក្រុមហ៊ុនមូលបត្រ | ឈ្មោះអ្នកធ្វើបរិវិសកម្ម |

---

[២] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

# គំរូវិក្កយបត្រ
# បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ នៃក្រុមហ៊ុនមូលបត្រ ..........................................**

លេខបរិវិសកម្ម :............................

កាលបរិច្ឆេទ : __/__/____

SPECIMEN

អ្នកធ្វើបរិវិសកម្មឈ្មោះ :...............................................................

លេខអត្តសញ្ញាណវិនិយោគិន :..................................................

ចំនួនទឹកប្រាក់សរុបបានទទួល :................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : ............................ ធនាគារ :............................................។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ

# ឧបសម្ព័ន្ធទី៤៖

# ពាក្យស្នើសុំធ្វើបរិវិសកម្ម
# មូលបត្រកម្មសិទ្ធិសម្រាប់
# វិនិយោគិនដែលមិនបាន
# ចូលរួមធ្វើប៊ុកបៀលឌីង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:..................................គ.ម.ក

ទម្រង់ទី ០៣

លេខបរិវិសកម្ម :...............................

## ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ សម្រាប់វិនិយោគិនដែលមិនបានចូលរួមធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយ.............................................

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវធ្វើសំណើលក់ជាសាធារណៈមានចំនួន ............................ ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ......................... ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ...................... ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់បុគ្គលិកមានចំនួន ................ ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនយុទ្ធសាស្ត្រ ........................ ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ...................... ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលែបម្រុងសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង .................................. ឯកតាមូលបត្រកម្មសិទ្ធិ។

ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ត្រូវមានចំនួនអប្បបរមាចាប់ពី .................................ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីការធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមាចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺស្មើនឹងចំនួនជងនៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មអប្បបរមា។

SPECIMEN

### ព័ត៌មានសម្រាប់វិនិយោគិនដែលចូលរួមក្នុងការធ្វើបរិវិសកម្ម

**ក. វិនិយោគិនជារូបវន្តបុគ្គល:**

☐រូបវន្តបុគ្គលសញ្ជាតិខ្មែរ ☐រូបវន្តបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :............................................ ជាអក្សរឡាតាំង :.........................................................

ថ្ងៃខែឆ្នាំកំណើត :................................................ ភេទ : ☐ ប្រុស ☐ ស្រី

ទូរស័ព្ទលេខ :....................................................... អ៊ីម៉ែល :............................................................... ។

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................... លេខគណនីជួញដូរ[១] :.................

[១] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

លេខអត្តសញ្ញាណវិនិយោគិន[២] :...........................................

**ខ. វិនិយោគិនជានីតិបុគ្គល:**

☐នីតិបុគ្គលសញ្ជាតិខ្មែរ ☐នីតិបុគ្គលមិនមែនសញ្ជាតិខ្មែរ

ឈ្មោះជាអក្សរខ្មែរ :.................................................. ជាអក្សរឡាតាំង :........................................................

លេខអត្តសញ្ញាណកម្មសារពើពន្ធ (ប្រសិនមាន) ......................................

ទូរស័ព្ទលេខ :............................................................ អ៊ីម៉ែល :..................................................................

ឈ្មោះក្រុមហ៊ុនមូលបត្រដែលបានបើកគណនីជួញដូរ :.................... លេខគណនីជួញដូរ[៣] :.................

លេខអត្តសញ្ញាណវិនិយោគិន[៤]:...........................................

រូបវន្តបុគ្គល ឬនីតិបុគ្គល អាចចូលរួមធ្វើបរិវិសកម្មតាមរយៈតំណាងរបស់ខ្លួនបានដោយមានលិខិតផ្ទេរសិទ្ធិត្រឹមត្រូវ។

SPECIMEN

## សំណើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

| ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលស្នើសុំធ្វើបរិវិសកម្ម | ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ចំនួនទឹកប្រាក់សរុបសម្រាប់ការស្នើសុំធ្វើបរិវិសកម្ម |
|---|---|---|
| ................................ | ................................ | ................................ |

## សេចក្តីថ្លែងសម្រាប់វិនិយោគិនដែលបានចូលរួមធ្វើបរិសកម្ម

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា÷

☐ ច្បាប់ចម្លង ☐ ឧបករណ៍ផ្ទុក (Storage device) ☐ អ៊ីម៉ែលផ្ទុក (E-mail storage)

☐ តាមរយៈគេហទំព័រ :.......................................ឬ ☐ ផ្សេងពីនេះ :.............................................

ការធ្វើបរិវិសកម្ម និងការទូទាត់ត្រូវធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិ

[២] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៣] ថតចម្លងលេខគណនីជួញដូរ ០១ ច្បាប់ ភ្ជាប់មកជាមួយ

[៤] ថតចម្លងលេខអត្តសញ្ញាណវិនិយោគិន ០១ ច្បាប់ ភ្ជាប់មកជាមួយ

បដិសេធក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញមូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឱ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។

**កាលបរិច្ឆេទស្នើសុំធ្វើបរិវិសកម្ម : __/__/____**

SPECIMEN

| | |
|---|---|
| ហត្ថលេខា ត្រា និងឈ្មោះ | ហត្ថលេខា ឬ/និងត្រា[៥] |
| ........................................ | ........................................ |
| តំណាងក្រុមហ៊ុនមូលបត្រ | ឈ្មោះអ្នកធ្វើបរិវិសកម្ម |

---

[៥] ករណីអ្នកធ្វើបរិវិសកម្មជានីតិបុគ្គល

# គំរូវិក្កយបត្រ
# បរិវិសកម្មមូលបត្រកម្មសិទ្ធិ

**វិក្កយបត្រការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនៃក្រុមហ៊ុន ..................................................**

លេខបរិវិសកម្ម :............................

កាលបរិច្ឆេទ : __/__/____

SPECIMEN

អ្នកធ្វើបរិវិសកម្មឈ្មោះ :.................................................................

លេខអត្តសញ្ញាណវិនិយោគិន :.......................................................

ចំនួនទឹកប្រាក់សរុបបានទទួល :.....................................................

មធ្យោបាយទូទាត់ : ☐ ប្រាក់សុទ្ធ

☐ បណ្ណឥណទាន

☐ មូលប្បទានបត្រលេខ : ........................... ធនាគារ :.......................................។

ហត្ថលេខា ត្រា និងឈ្មោះ

តំណាងក្រុមហ៊ុនមូលបត្រ